# អភិធម្មត្ថសង្គហៈ

## បរិច្ឆេទទី ២

## ចេតសិកសង្គហវិភាគ

នៅក្នុងបរិច្ឆេទនេះព្រះអនុរុទ្ធាចារ្យលោកបានតាំងគាថាផ្ដើមទុកថា ៖-

**ឯកុប្បាទនិរោធា ច ឯកាលម្ពន វត្ថុកា**

**ចេតោយុត្តា ទ្វិបញ្ញាស ធម្មា ចេតសិកា មតា**

ប្រែថា ធម៌ទាំងឡាយ ៥២ ដែលប្រកបជាមួយនិងចិត្តគឺ មានការកើតឡើងជាមួយនិងចិត្តមានការរលត់ជាមួយនិងចិត្ត មានអារម្មណ៍តែមួយជាមួយនិងចិត្ត មានវត្ថុតែមួយជាមួយនិងចិត្ត ឈ្មោះថា **ចេតសិក**។ ចេតសិកជាធម្មជាតិ ដែលត្រូវអាស្រ័យនិងចិត្តកើតឡើងនេះមានសេចក្ដីថា ប្រៀបដូចសិស្ស និងអាចារ្យ គឺមានសិស្សក៏ត្រូវមានអាចារ្យ ឬមានអាចារ្យ ក៏ត្រូវមានសិស្ស និងអត់ណាមួយមិនបាន សភាវៈទាំងពីរនេះប្រាកដព្រមគ្នាដូចមានវចនត្ថថា **ចេតសិ ភវំ ចេតសិកំ វា ចេតសិ និយុត្តំ ចេតសិកំ** ប្រែថា ធម្មជាតិកើតក្នុងចិត្ត ឬប្រកបក្នុងចិត្តឈ្មោះថា **ចេតសិក**។ ម្យ៉ាងទៀត អាការៈដែលចេតសិកប្រកបជាមួយនិងចិត្តនោះឯងលោកហៅថា **ចេតោយុត្តលក្ខណៈ** ព្រោះប្រកបជាមួយនិងចិត្តជានិច្ចតាម លក្ខណៈ ៤ យ៉ាងគឺ ៖-

១-**ឯកុប្បាទ** កើតព្រមជាមួយនិងចិត្ត

២-**ឯកនិរោធ** រលត់ព្រមជាមួយនិងចិត្ត

៣-**ឯកាលម្ពណ** មានអារម្មណ៍តែមួយជាមួយនិងចិត្ត

៤-**ឯកវត្ថុក** មានទីកើតតែមួយជាមួយនិងចិត្ត

## លក្ខណាទិចតុក្ករបស់ចេតសិក

-លក្ខណៈរបស់ចេតសិក

**ចិត្តនិស្សិតលក្ខណំ** មានការអាស្រ័យនិងចិត្តជាលក្ខណៈ

-កិច្ចរបស់ចេតសិក

**អវិយោគុប្បាទនរសំ** មានការកើតរួមជាមួយនិងចិត្តជាកិច្ច

-ផល ឬ អាការៈប្រាកដរបស់ចេតសិក

**ឯកាលម្ពណបច្ចុប្បដ្ឋានំ** មានអារម្មណ៍ជាមួយនិងចិត្តជាផល

-ហេតុ ឬ បទដ្ឋានរបស់ចេតសិក

**ចិត្តុប្បាទបទដ្ឋានំ** មានការកើតនៃចិត្តជាហេតុជិត ។

ចិត្តនិងចេតសិកទាំងពីរនេះជានាមធម៌ដូចគ្នាទើប ប្រកបជាមួយគ្នាបានយ៉ាងជិតស្និតដូចជាភាពតែមួយ ក៏ប៉ុន្តែ តាមការពិតនោះ គឺផ្សេងគ្នាចិត្តមាននាទីជាប្រធាន ឬជាអធិបតីក្នុងការដឹងអារម្មណ៍ចំណែកចេតសិកមានការកើតរួមជាមួយនិងចិត្ត ហើយតាក់តែងចិត្តឱ្យប្រព្រឹត្តទៅជាសភាពផ្សេង ៗ ដូច្នេះរួមសេចក្តីមកចិត្ត និងចេតសិកគឺផ្សេងគ្នាត្រង់កិច្ច ឬ តួនាទីប៉ុណ្ណោះ ។

ចេតសិកមាន ៥២ ចែកចេញជា ៣ ពួកគឺ ៖-

**១-អញ្ញសមានាចេតសិក** មាន ១៣

**២-អកុសលចេតសិក** មាន ១៤

**៣-សោភណចេតសិក** មាន ២៥

## អញ្ញសមានាចេតសិក

អញ្ញសមានាចេតសិកជាចេតសិកធម៌មួយពួកស្មើនិងធម៌ដទៃទៀត គឺប្រកបជាមួយនិងចិត្តជាកុសល ក៏បានទៅជាកុសល បើប្រកបជាមួយនិងចិត្តជាអកុសល ក៏បានទៅជាអកុសល បើប្រកបជាមួយនិងអព្យាកតចិត្ត ក៏និងបានទៅជាអព្យាកត ព្រោះហេតុនោះទើបលោកហៅថា **អញ្ញសមានាចេតសិក** លោកចែកចេញជា ២ ពួកគឺ **សព្វចិត្តសាធារណចេតសិក ១** និង **បកិណ្ណកចេតសិក ១** ។

## សព្វចិត្តសាធារណចេតសិក

សព្វចិត្តសាធារណចេតសិកជាចេតសិកធម៌ដែលទូទៅដល់ចិត្តទាំងពួងគឺប្រកបជាមួយនិងចិត្តគ្រប់ដួង ទាំងអស់មាន ៧ គឺ ៖-

**១-ផស្សចេតសិក** មានការប៉ះខ្ទប់ជាលក្ខណៈ

**២-វេទនាចេតសិក** មានការសោយនូវអារម្មណ៍ជាលក្ខណៈ

**៣-សញ្ញាចេតសិក** មានការចងចាំជាលក្ខណៈ

**៤-ចេតនាចេតសិក** មានការតាំងចិត្តជាលក្ខណៈ

**៥-ឯកគ្គតាចេតសិក** មានការមិនរវើរវាយជាលក្ខណៈ

**៦-ជីវិតិន្ទ្រិយចេតសិក** មានការអនុបាលរក្សាសហជាតធម៌ជាលក្ខណៈ

**៧-មនសិការចេតសិក** មានការបង្រួបបង្រួមសហជាតធម៌ជាលក្ខណៈ

## អធិប្បាយអំពីសព្វចិត្តសាធារណចេតសិក

**១-ផស្សចេតសិក** វចនត្ថរបស់ផស្សៈចេតសិក **ផុស្សតីតិ ផស្សោ** ជាធម្មជាតិដែលបានឈ្មោះថាផស្សៈ ព្រោះមានវចនត្ថថា ប៉ះខ្ទប់ ឬពាល់ត្រូវ។ ផស្សៈនេះលោកហៅថាផស្សាហារ ព្រោះតែអាហារនេះគឺជាបច្ច័យ។ ផស្សៈនេះព្រះនាគសេនត្ថេរ លោកបានវិជ្ជនាដល់ព្រះចៅក្រុងមិលិន្ទថា "ដូចជាពពែពីរក្បាលជល់គ្នា ពពែមួយលោកប្រៀបដូចជាចក្ខុបសាទ ពពែមួយទៀតលោកទុកដូចជារូប (វណ្ណៈ)"។ ផស្សៈចេតសិកនេះ មានអត្ថថាប៉ះខ្ទប់ គឺប៉ះខ្ទប់នូវអារម្មណ៍ហើយមានកិច្ច គឺនាទីធ្វើឱ្យអារម្មណ៍និងចិត្តប៉ះខ្ទប់គ្នាជាបច្ច័យធ្វើឱ្យធមិ ៣ យ៉ាង គឺអារម្មណ៍ ១ វត្ថុ ១ និងវិញ្ញាណ ១ ប្រជុំគ្នាជាអាការៈប្រាកដ ម្យ៉ាងទៀតលោកពោលថា ផស្សៈនេះមានវេទនាជាផល ។ បណ្ឌិតគប្បីឃើញថា ផស្សៈនេះដូចជាមេគោដែលត្រូវគេបកស្បែកហើយ ព្រោះជាទីតាំងនៃវេទនា។ ការដែលផស្សៈប៉ះខ្ទប់និងអារម្មណ៍មិនដូចជារូប និងរូបប៉ះខ្ទប់គ្នាទេ ព្រោះផស្សៈជានាមធមិមានគុណសម្បត្តិអាចប៉ះខ្ទប់អារម្មណ៍រូប ក៏បានជាអារម្មណ៍ ឬអារម្មណ៍ជានាមក៏បានក្នុងខណៈដែលចិត្តដឹងអារម្មណ៍ ផស្សៈនេះ រមែងធ្វើនាទីប៉ះខ្ទប់ ទោះអារម្មណ៍នោះជាលោកិយារម្មណ៍ ឬក៏លោកុត្តរារម្មណ៍ ព្រះនិព្វាន ក៏ដោយ ផស្សៈក៏ជាបច្ច័យសំខាន់ដល់សម្បយុត្តធមិទាំងនោះ ។

## លក្ខណាទិចតុករបស់ផស្សចេតសិក

-លក្ខណៈរបស់ផស្សចេតសិក

**ផុសនលក្ខណោ** មានការប៉ះខ្ទប់ជាលក្ខណៈ ។

-កិច្ច របស់ផស្សចេតសិក

**សង្ឃដ្ដនរសោ** មានការធ្វើឱ្យចិត្តនិងអារម្មណ៍ប៉ះខ្ទប់គ្នាជាកិច្ច ។

-ផល ឬអាការៈប្រាកដ របស់ផស្សចេតសិក

**សន្និបាតបច្ចុប្បដ្ឋានោ** មានការប្រជុំនូវអារម្មណ៍ វត្ថុ និងចិត្ត ជាផល ។

-ហេតុ ឬបទដ្ឋានរបស់ផស្សចេតសិក

**អាបាថគតវិសយបទដ្ឋានោ** មានអារម្មណ៍មកកាន់គន្លងជាហេតុជិត ។

ត្រង់កិច្ច ឬអាការៈប្រាកដរបស់ផស្សចេតសិកដែលមានការប្រជុំព្រមនូវអាម្មរណ៍ វត្ថុ និងចិត្តជាផលនោះ សមដូចព្រះតម្រាស់របស់ព្រះមានព្រះភាគទ្រង់សំដែងទុកក្នុងនិទានវគ្គសំយុត្តថា សំយុត្តថា ៖- **ចក្ខុញ្ច បដិច្ច រូបេ ច ឧប្បជ្ជតិ ចក្ខុវិញ្ញាណំ តិណ្ណំ សង្គតិ ផស្សោ សោតញ្ច បដិច្ច សទ្ទេ ច ឧប្បជ្ជតិ សោតវិញ្ញាណំ តិណ្ណំ សង្គតិ**

-

**ផស្សោ ឃានញ្ច បដិច្ច គន្ធេ ច ឧប្បជ្ជតិ ឃានវិញ្ញាណំ តិណ្ណំ សង្គតិ ផស្សោ ជិវ្ហញ្ច បដិច្ច រសេ ច ឧប្បជ្ជតិ ជិវ្ហាវិញ្ញាណំ តិណ្ណំ សង្គតិ ផស្សោ កាយញ្ច បដិច្ច ផោដ្ឋព្វេ ច ឧប្បជ្ជតិ កាយវិញ្ញាណំ តិណ្ណំ សង្គតិ ផស្សោ មនញ្ច បដិច្ច ធម្មេ ច ឧប្បជ្ជតិ មនោវិញ្ញាណំ តិណ្ណំ សង្គតិ ផស្សោ** ប្រែថា ចក្ខុវិញ្ញាណរមែងប្រាកដឡើងបាន ព្រោះអាស្រ័យចក្ខុបសាទជាមួយរូបារម្មណ៍ ការប្រជុំរួមគ្នារវាងចក្ខុបសាទ រូបារម្មណ៍ ចក្ខុវិញ្ញាណទាំង ៣ នេះឈ្មោះថាផស្សៈ។ សោតវិញ្ញាណ រមែងប្រាកដឡើងបានព្រោះអាស្រ័យសោតបសាទជាមួយសទ្ទារម្មណ៍ ការប្រជុំរួមគ្នារវាងសោតបសាទ សោត-វិញ្ញាណទាំង ៣ នេះឈ្មោះថា ផស្សៈ។ ឃានវិញ្ញាណរមែងប្រាកដឡើងបានព្រោះអាស្រ័យឃានបសាទជាមួយគន្ធារម្មណ៍ ការប្រជុំរួមគ្នារវាងឃានបសាទ គន្ធារម្មណ៍ ទាំងឃានវិញ្ញាណ ៣ នេះឈ្មោះថា ផស្សៈ។ ជីវ្ហាវិញ្ញាណរមែងប្រាកដឡើងបាន ព្រោះអាស្រ័យជីវ្ហាបសាទជាមួយរសារម្មណ៍ ការប្រជុំ រួមគ្នារវាងជីវ្ហាបសាទ រសារម្មណ៍ ជីវ្ហាវិញ្ញាណទាំង ៣ នេះឈ្មោះថា ផស្សៈ។ កាយវិញ្ញាណ រមែងប្រាកដឡើងបានព្រោះអាស្រ័យកាយបសាទជាមួយផោដ្ឋព្វារម្មណ៍ ការប្រជុំរួមគ្នារវាងកាយបសាទ ផោដ្ឋព្វារម្មណ៍ កាយវិញ្ញាណទាំង ៣ នេះឈ្មោះថា ផស្សៈ។ មនោវិញ្ញាណរមែងប្រាកដឡើងបានព្រោះអាស្រ័យភវង្គចិត្តជាមួយនិងសភាវៈធម៌ផ្សេងៗ រួមទាំងបរមត្ថ និងបញ្ញត្តិ ការប្រជុំរួមគ្នារវាងភវង្គចិត្ត សភាវៈធម៌ផ្សេងៗ មនោវិញ្ញាណទាំង៣ នេះឈ្មោះថាផស្សៈ។

**២.វេទនាចេតសិក** វចនត្ថរបស់វេទនាចេតសិក ***អាលម្ពណរសំ អនុភវតីតិ វេទនា*** ប្រែថា ធម្មជាតិដែលបានឈ្មោះថាវេទនា ព្រោះអត្ថថាសោយនូវរសនៃអារម្មណ៍។ សម្បយុត្តធម៌ក្រៅអំពីវេទនានេះក៏មានការសោយនូវរសនៃអារម្មណ៍ដែរ ក៏ប៉ុន្តែសោយបានត្រឹមតែមួយ ចំណែក (ឯកទេស) ប៉ុណ្ណោះ ចំណែកវេទនាវិញគឺសោយនូវរសគឺអារម្មណ៍ ដោយពេញលេញ ឬដោយត្រង់តែម្តង ព្រោះថាវេទនានេះមានភាពជាអធិបតី (ជាប្រធាន) ក្នុងការសោយនូវអារម្មណ៍ ។ ក្នុងអត្ថសាលិនី អដ្ឋកថាធម្មសង្គណីបករណ៍មានសេចក្តីប្រៀបធៀបថា វេទនាទុកដូចជាព្រះរាជាអ្នកសោយនូវព្រះក្រយាហារ ចំណែកចិត្តនិងចេតសិកព្រមទាំងសម្បយុត្តធម៌ដទៃទៀតលោកទុកដូចជាអ្នកដាំស្លរនូវព្រះក្រយាហារថ្វាយព្រះរាជា ។ ដូច្នេះអ្នកដាំស្លរមានសិទ្ធិត្រឹមតែភ្លក្សអាហារនោះប៉ុណ្ណោះ មិនដូចព្រះរាជាទេទ្រង់មានសិទ្ធិគ្រប់គ្រាន់នៅក្នុងការសោយ ។ វេទនានេះកាលបើចែកតាមអារម្មណានុភវលក្ខណន័យ គឺន័យក្នុងការសោយអារម្មណ៍ជាលក្ខណៈមាន ៣ គឺសុខវេទនា ១ ទុក្ខវេទនា ១ អទុក្ខមសុខវេទនា ១។ ប៉ុន្តែ

-

បើចែកតាមឥន្ទ្រិយវិញមាន ៥ គឺសុខវេទនា ១ ទុក្ខវេទនា ១ សោមនស្សវេទនា ១ ទោមនស្សវេទនា ១ ឧបេក្ខាវេទនា ១ ។

## លក្ខណាទិចតុក្ករបស់វេទនាចេតសិក

-លក្ខណៈរបស់វេទនាចេតសិក

**អនុភវនលក្ខណា** មានការសោយនូវរសអារម្មណ៍ជាលក្ខណៈ ។

-កិច្ចរបស់វេទនាចេតសិក

**វិសយរសសម្ភោគរសា** មានការប្រសព្វនិងរសរបស់អារម្មណ៍ជាកិច្ច ។

-ផលរឺអាការៈប្រាកដរបស់វេទនាចេតសិក

**សុខទុក្ខបច្ចុប្បដ្ឋានា** មានសុខនិងទុក្ខជាផល ។

-ហេតុ ឬ បទដ្ឋានរបស់វេទនាចេតសិក

**ផស្សបទដ្ឋានោ** មានផស្សៈជាហេតុជិត ។

## លក្ខណាទិតុក្ករបស់សុខវេទនា

-លក្ខណៈរបស់សុខវេទនា

**ឥដ្ឋផោដ្ឋព្វានុភវនលក្ខណោ** មានការសោយផោដ្ឋព្វៈយ៉ាងគាប់ចិត្តជាលក្ខណៈ ។

-កិច្ចរបស់សុខវេទនា

**សម្បយុត្តានំ ព្រូហនរសា** មានការញ៉ាំងសម្បយុត្តធម៌អោយចំរើនឡើងជាកិច្ច ។

-ផល ឬអាការៈប្រាកដរបស់សុខវេទនា

**កាយិកអស្សាទបច្ចុប្បដ្ឋានា** មានការសប្បាយកាយជាផល ។

-ហេតុ ឬបទដ្ឋានរបស់សុខវេទនា

**កាយិន្ទ្រិយបទដ្ឋានា** មានកាយបសាទជាហេតុជិត ។

## លក្ខណាទិចតុក្ករបស់ទុក្ខវេទនា

-លក្ខណៈរបស់ទុក្ខវេទនា

**អនិដ្ឋផោដ្ឋព្វានុភវនលក្ខណា** មានការសោយនូវផោដ្ឋព្វៈមិនជាទីប្រាថ្នាជាលក្ខណៈ ។

-កិច្ចរបស់ទុក្ខវេទនា

**សម្បយុត្តានំ មិលាបនរសា** មានការញ៉ាំងសម្បយុត្តធម៌ឱ្យថយចុះគឺសៅហ្មងជាកិច្ច ។

-ផល ឬអាការៈប្រាកដរបស់ទុក្ខវេទនា

-

**កាយិកាពាធបច្ចុប្បដ្ឋានា** មានការអាពាធកាយជាផល ។

-ហេតុ ឬបទដ្ឋានរបស់ទុក្ខវេទនា

**កាយិន្ទ្រិយបទដ្ឋានា** មានកាយបសាទជាហេតុជិត ។

**លក្ខណាទិចតុក្ករបស់សោមនស្សវេទនា**

-លក្ខណៈរបស់សោមនស្សវេទនា

**ឥដ្ឋារម្មណានុភវនលក្ខណា** មានការសោយនូវអារម្មណ៍យ៉ាងគាប់ចិត្តជាលក្ខណៈ ។

-កិច្ចរបស់សោមនស្សវេទនា

**ឥដ្ឋាការសម្ភោគរសា** មានការប្រសព្វនិងអាការៈជាទីប្រាថ្នាជាកិច្ច ។

-ផល ឬអាការៈប្រាកដ របស់សោមនស្សវេទនា

**ចេតសិកអស្សាទបច្ចុប្បដ្ឋានា** មានការសប្បាយចិត្តជាផល ។

-ហេតុ ឬបទដ្ឋាន របស់សោមនស្សវេទនា

**បស្សទ្ធិបទដ្ឋានា** មានការស្ងប់កាយស្ងប់ចិត្តជាហេតុជិត ។

**លក្ខណាទិចតុក្ករបស់ទោមនស្សវេទនា**

-លក្ខណៈរបស់ទោមនស្សវេទនា

**អនិដ្ឋារម្មណានុភវនលក្ខណា** មានការសោយអារម្មណ៍មិនជាទីគាប់ចិត្តជាលក្ខណៈ

-កិច្ចរបស់ទោមនស្សវេទនា

**អនិដ្ឋាការសម្ភោគរសា** មានការប្រសព្វនិងអាការៈមិនជាទីគាប់ចិត្តជាកិច្ច ។

-ផល ឬអាការៈប្រាកដ របស់ទោមនស្សវេទនា

**ចេតសិកាពាធបច្ចុប្បដ្ឋានា** មានការអាពាធចិត្តជាផល ។

-ហេតុ ឬបទដ្ឋាន របស់ទោមនស្សវេទនា

**ឯកន្តេនេវ ហទយវត្ថុបទដ្ឋានា** មានតែហទយវត្ថុប៉ុណ្ណោះជាហេតុជិត ។

**លក្ខណាទិចតុក្ករបស់ឧបេក្ខាវេទនា**

-លក្ខណៈរបស់ឧបេក្ខាវេទនា

**មជ្ឈត្តវេទយិតលក្ខណា** មានការសោយអារម្មណ៍ជាកណ្តាលជាលក្ខណៈ ។

-កិច្ច របស់ឧបេក្ខាវេទនា

-

**សម្បយុត្តានំ នាតិ ឧបព្រូហនមិលាបនរសា** មានការរក្សាសម្បយុត្តធម៌មិនឱ្យចំរើនឡើងនិងមិនឱ្យសៅហ្មងវិនាសជាកិច្ច ។

-ផល ឬអាការៈប្រាកដ របស់ឧបេក្ខាវេទនា

**សន្ត ភាវបច្ចុប្បដ្ឋានា** មានការស្ងប់ស្ងាត់ព្រងើយជាផល ។

-ហេតុ ឬបទដ្ឋាន របស់ឧបេក្ខាវេទនា

**និប្បិតិកចិត្តបទដ្ឋានា** មានចិត្តដែលប្រកបដោយបីតិជាហេតុជិត ។

**ឧបេក្ខា ១០**

ឧបេក្ខានេះមាន ១០ យ៉ាងគឺ ៖-

១-ឧបេក្ខាណា ជាធម៌ដ៏បរិសុទ្ធជាប្រក្រតីក្នុងគន្លងនៃអារម្មណ៍ទាំង ៦ ដែលជាទីប្រាថ្នាក្តីមិនជាទីប្រាថ្នាក្តីក្នុងទ្វារទាំង ៦ របស់ព្រះខីណាស្រពឈ្មោះថា **ឆឡង្គុបេក្ខា** ឧបេក្ខានេះបានដល់ **តត្រមជ្ឈត្តតាចេតសិក** ។

២-ឧបេក្ខាណា មានអាការៈជាកណ្តាលក្នុងសត្វទាំងឡាយឈ្មោះថា **ព្រហ្មវិហារុបេក្ខា** គឺឧបេក្ខានៅក្នុងព្រហ្មវិហារធម៌បានដល់ **តត្រមជ្ឈត្តតាចេតសិក** ។

៣-ឧបេក្ខាណា ដែលប្រព្រឹត្តទៅស្មោះស្មើជានិច្ចដែលមាននៅក្នុងយេវាបនកធម៌មានឆន្ទៈជាដើម ឧបេក្ខានេះឈ្មោះថា **តត្រមជ្ឈត្តុបេក្ខា** បានដល់ **តត្រមជ្ឈត្តតាចេតសិក ។**

៤-ឧបេក្ខាណា ពោលគឺសេចក្តីព្យាយាមមិនបន្ធូរបន្ថយ គឺព្យាយាមឱ្យកើតឡើងសព្វកាលកើតឡើង ឧបេក្ខានេះឈ្មោះថា **វិរិយុបេក្ខា** ឧបេក្ខាគឺសេចក្តីព្យាយាមបានដល់ **វិរិយចេតសិក**

៥-ឧបេក្ខាណា ដែលសំគាល់ដឹងក្នុងសភាពមិនសុខមិនទុក្ខឈ្មោះថា វេទនុបេក្ខាបានដល់ឧបេក្ខាវេទនា ។

៦-ឧបេក្ខាណា មានសភាពជាកណ្តាលក្នុងសហជាតធម៌ព្រោះអាស្រ័យវិវេកឧបេក្ខានេះឈ្មោះថា **ពោជ្ឈង្គុបេក្ខា** គឺឧបេក្ខាក្នុងសម្ពោជ្ឈង្គ បានដល់តត្រមជ្ឈត្តតាចេតសិក ។

៧-ឧបេក្ខាណា ដែលមានអាការៈជាកណ្តាលកំណត់ពិចារណាសភាវៈធម៌មាននីវរណធម៌ជាដើម ឧបេក្ខាមានសភាពបែបនេះឈ្មោះថា**សង្ខារុបេក្ខា** បានដល់**បញ្ញាចេតសិក** ។

៨-ឧបេក្ខាណា ដែលមានសភាពជាកណ្តាលក្នុងការសង្កេតពិចារណានូវសភាវៈធម៌ណាដែលកំពុងប្រាកដហើយលះបង់នូវសភាវៈធម៌នោះចេញឧបេក្ខាមានសភាព បែបនេះ ឈ្មោះថា **វិបស្សនុបេក្ខា** បានដល់ បញ្ញាចេតសិក ។

-

៩-ឧបេក្ខាណា ដែលមានកិរិយាបង្អោនចុះទៅកាន់សេចក្តីនៃឈានដែលជាសុខដ៏ប្រសើរឧបេក្ខានេះឈ្មោះថា **ឈានុបេក្ខា** បានដល់តត្រមជ្ឈត្តតាចេតសិក ។

១០-ឧបេក្ខាណា ដែលបរិសុទ្ធចាកអំពីបច្ចនិកធមិមិនខ្វល់ខ្វាយ សូម្បីក្នុងការស្ងប់ដូចជានៅឈានទី ៤ មានសតិបរិសុទ្ធព្រោះឧបេក្ខាយ៉ាងនេះជាដើម ឧបេក្ខានេះឈ្មោះថា **បារិសុទ្ធិឧបេក្ខា** បានដល់ តត្រមជ្ឈត្តតាចេតសិក ។

បណ្តាឧបេក្ខាទាំងនោះ **ឆឡង្គុបេក្ខា ព្រហ្មវិហារុបេក្ខា ពោជ្ឈង្គុបេក្ខា តត្រមជ្ឈត្តុតាបេក្ខា ឈានុបេក្ខា បារិសុទ្ធុបេក្ខា** ឧបេក្ខា ៦ នេះដោយអត្ថជាតត្រមជ្ឈត្តុតាចេតសិក ប៉ុន្តែខុសគ្នាផ្សេងៗ គ្នាដោយប្រភេទប្រៀបដូចបុគ្គលម្នាក់ គឺក្នុងកាលជាកុមារ ជាកំលោះ ជាអ្នកធំ ជាសេនាបតី ជាព្រះរាជា ជាដើម ។

ឧបេក្ខាពីរយ៉ាងគឺ សង្ខារុបេក្ខា ១ វិបស្សនុបេក្ខា ១ ជាបញ្ញាចេតសិក ប៉ុន្តែផ្សេងគ្នាត្រង់កិច្ចគឺថា **វិបស្សនុបេក្ខា** ជាបច្ច័យឱ្យសង្ខារុបេក្ខាកើតឡើង ។

ឧបេក្ខាពីរទៀត **វីរិយុបេក្ខា ១** បានដល់វីរិយចេតសិកនិង **វេទនុបេក្ខា ១** បានដល់ឧបេក្ខាវេទនាចេតសិក ។

**សេចក្តីបញ្ជាក់** ត្រង់បទដ្ឋានរបស់វេទនាចេតសិកដែលលោកសំដែងថា **ផស្សបទដ្ឋានា** មានផស្សៈជាហេតុជិត។ ដោយន័យនេះឃើញថាវេទនានេះកើត ព្រោះផស្សៈជាបច្ច័យដោយហេតុនេះនៅក្នុងបដិច្ចសមុប្បាទលោកសំដែងថា**ផស្សប្បច្ចយា វេទនា សម្ភវតិ** ប្រែថា វេទនា ៦ រមែងប្រាកដកើតឡើងព្រោះអាស្រ័យផស្សៈទាំង ៦ជាហេតុគឺ ៖-

**១. ចក្ខុសម្ផស្សជា វេទនា** ការសោយអារម្មណ៍ដែលកើតឡើងដោយ អាស្រ័យការប៉ះខ្ទប់គ្នារវាងចក្ខុវិញ្ញាណជាមួយរូបារម្មណ៍ បានដល់វេទនាដែលតាំងនៅក្នុងចក្ខុវិញ្ញាណចិត្ត ។

**២. សោតសម្ផស្សជា វេទនា** ការសោយអារមណ៍ដែលកើតឡើងដោយអាស្រ័យការប៉ះខ្ទប់គ្នា រវាង សោតវិញ្ញាណ

ជាមួយសទ្ទារម្មណ៍ បានដល់វេទនាដែលតាំងនៅក្នុងសោតវិញ្ញាណចិត្ត ។

**៣. ឃានសម្ផស្សជា វេទនា**

ការសោយអារមណ៍ដែលកើតឡើងដោយអាស្រ័យការប៉ះខ្ទប់គ្នារវាងឃានវិញ្ញាណជាមួយគន្ធារម្មណ៍ បានដល់វេទនាដែលតាំងនៅក្នុងឃានវិញ្ញាណចិត្ត ។

-

**៤.ជិវ្ហាសម្ផស្សជា វេទនា**

ការសោយអារម្មណ៍ដែលកើតឡើងដោយអាស្រ័យការប៉ះខ្ទប់គ្នារវាងជីវ្ហាវិញ្ញាណជាមួយរសារម្មណ៍ បានដល់វេទនាដែលតាំងនៅជីវ្ហាវិញ្ញាណចិត្ត ។

**៥.កាយសម្ផស្សជា វេទនា**

ការសោយអារម្មណ៍ដែលកើតឡើងដោយអាស្រ័យការប៉ះខ្ទប់គ្នារវាងកាយវិញ្ញាណជាមួយផោដ្ឋព្វារម្មណ៍ បានដល់វេទនាដែលតាំងនៅក្នុងកាយវិញ្ញាណចិត្ត ។

**៦.មនោសម្ផស្សជា វេទនា**

ការសោយអារម្មណ៍ដែលកើតឡើងដោយអាស្រ័យការប៉ះខ្ទប់គ្នារវាងមនោវិញ្ញាណជាមួយធម្មារម្មណ៍ ឬ អារម្មណ៍ទាំង ៦ បានដល់វេទនាដែលតាំងនៅក្នុងលោកិយវិបាកចិត្ត ២២ វៀរទ្វិបញ្ចវិញ្ញាណ ។

តាមសេចក្តីនេះឃើញថាវេទនានេះឯងកើតឡើងព្រោះតែផស្សៈទាំង ៦ជាហេតុហើយធ្វើឱ្យវេទនានេះមានឈ្មោះ ៦-

យ៉ាងទៀតដោយអាស្រ័យការប៉ះខ្ទប់ជាមួយសភាវៈផ្សេងៗដែលមានន័យដូចតទៅនេះ

**ចក្ខុសម្ផស្សតោ ជាតា វេទនាតិ ចក្ខុសម្ផស្សជា វេទនា សោតសម្ផស្សតោ ជាតា វេទនាតិ សោតស្សមស្សជា វេទនា ឃានសម្ផស្សតោ ជាតា វេទនាតិ ឃានសម្ផស្សជា វេទនា ជិវ្ហាសម្ផស្សតោ**

**ជាតា វេទនាតិ ជិវ្ហាសម្ផស្សជា វេទនា កាយសម្ផស្សតោ ជាតា វេទនាតិ កាយសម្ផស្សជា វេទនា**

**មនោសម្ផស្សតោ ជាតា វេទនាតិ មនោសម្ផស្សជា វេទនា** ប្រែថា

វេទនាដែលកើតឡើងព្រោះអាស្រ័យចក្ខុសម្ផស្សៈជាហេតុដូច្នេះទើបឈ្មោះថា ចក្ខុសម្ផស្សជាវេទនា

វេទនាដែលកើតឡើងព្រោះអាស្រ័យសោតសម្ផស្សៈជាហេតុដូច្នេះទើបឈ្មោះថា សោតសម្ផស្សជាវេទនា

វេទនាដែលកើតឡើងព្រោះអាស្រ័យឃានសម្ផស្សៈជាហេតុទើបឈ្មោះថា ឃានសម្ផស្សជាវេទនា វេទនាដែលកើតឡើងព្រោះអាស្រ័យជីវ្ហាសម្ផស្សៈជាហេតុទើបឈ្មោះថា ជីវ្ហាសម្ផស្សជាវេទនា

-

វេទនាដែលកើតឡើងព្រោះអាស្រ័យកាយសម្ផស្សៈជាហេតុទើបឈ្មោះថា កាយសម្ផស្សជាវេទនា វេទនាដែលកើត-

ឡើងព្រោះអាស្រ័យមនោសម្ផស្សៈជាហេតុទើបឈ្មោះថា មនោសម្ផស្សជាវេទនា ។

ដោយន័យនេះអ្នកសិក្សាទាំងឡាយ

គប្បីជ្រាបបានដោយន័យដែលពោលមកហើយនេះចុះ ។

**៣-សញ្ញាចេតសិក**

☞ វចនត្ថរបស់សញ្ញាចេតសិក នីលាទិភេទារម្មណំ សញ្ជានាតិ សញ្ញំ កត្វា ជានាតីតិ សញ្ញា ប្រែថា ធម្មជាតិដែលបាន

ឈ្មោះថា សញ្ញាព្រោះមានវចនត្ថថា ចងចាំនូវអារម្មណ៍ផ្សេងៗមានអារម្មណ៍ពណ៌ខៀវជាដើមគឺថា ធ្វើគ្រឿងចំណាំដឹង។

**លក្ខណាទិចតុករបស់សញ្ញាចេតសិក**

-លក្ខណៈរបស់សញ្ញាចេតសិក

☞ សញ្ជាននលក្ខណា មានការចងចាំជាលក្ខណៈ ។

-កិច្ចរបស់សញ្ញាចេតសិក

☞ បុនសញ្ជាននបច្ចយនិមិត្តករណរសា

មានការធ្វើគ្រឿងចំណាំព្រោះអាស្រ័យការចងចាំក្នុងពេលមុនជាកិច្ច ។

-ផល ឬ អាការៈប្រាកដរបស់សញ្ញាចេតសិក

☞ យថាគហិតនិមិត្តវសេន អភិនិវេសករណបច្ចុប្បដ្ឋានា

មានការធ្វើទុកក្នុងការប្រកាន់យកដោយអំណាចនៃគ្រឿងសំគាល់ដែលបានកាន់យកហើយតាមសមគួរជាផល

-ហេតុ ឬ បទដ្ឋានរបស់សញ្ញាចេតសិក

☞ យថាឧបដ្ឋិតវិសយបទដ្ឋានា មានអារម្មណ៍ដែលចូលទៅតាំងនៅប្រាកដជាហេតុជិត ។

**៤-ចេតនាចេតសិក**

☞ វចនត្ថរបស់ចេតនាចេតសិក ចេតេតិ អត្តនា សម្បយុត្តធម្មេ អារម្មណេ អភិសន្ទហតិ សង្ខតាភិសង្ខរណេ វា ព្យាបារមាបជ្ជតីតិ ចេតនា ប្រែថា ធម្មជាតិដែលបានឈ្មោះថា ចេតនាព្រោះមានវចនត្ថថា តាំងចិត្តគឺថា ញុំាំងសម្បយុត្ត

-

ធមិឱ្យព្រមព្រៀងជាមួយនិងខ្លួនក្នុងអារម្មណ៍ ឬ

ឈ្មោះថាចេតនាព្រោះមានវចនត្ថថាដល់នូវសេចក្តីខ្វល់ខ្វាយក្នុងការ

តាក់តែងដែលជាសង្ខតធមិ ។ ចេតនាចេតសិកនេះជាធម្មជាតិដែលតាំងចិត្តចាត់ចែង ជំរុញ

លើកស្ទួយដាក់តឿននូវសម្បយុត្តធមិដែលកើតព្រមជាមួយខ្លួនឱ្យធ្វើកិច្ចរបស់ខ្លួនរៀងៗខ្លួន ។

ដោយហេតុដូច្នេះហើយកាលព្រះមានព្រះភាគ

ទ្រង់ត្រាស់ចែកសង្ខារក្ខន្ធព្រះអង្គទ្រង់មានព្រះតម្រាស់ថា ចេតនា ឈ្មោះថា

សង្ខារព្រោះអត្ថថាតាក់តែងនូវធមិដែលជា

សង្ខត ។

## លក្ខណាទិចតុក្ករបស់ចេតនាចេតសិក

-លក្ខណៈរបស់ចេតនាចេតសិក

☞ ចេតនាភាវលក្ខណា មានការតាំងចិត្តជាលក្ខណៈ ។

-កិច្ចរបស់ចេតនាចេតសិក

☞ អាយូហនរសា មានការព្យាយាមប្រមូលមកជាកិច្ច ។

-ផល ឬអាការៈប្រាកដរបស់ចេតនាចេតសិក

☞ សំវិធានបច្ចុប្បដ្ឋានា

មានការចាត់ចែងគឺញុំាងកិច្ចរបស់ខ្លួននិងសម្បយុត្តធមិដ៏ទៃទៀតឱ្យសំរេចជាផល ។

-ហេតុ ឬ បទដ្ឋានរបស់ចេតនាចេតសិក

☞ *សេសក្ខន្ធត្តយបទដ្ឋានា* មាននាមក្ខន្ធ ៣គឺ វេទនា សញ្ញា វិញ្ញាណ ដែលសេសជាហេតុជិត ។

**៥-ឯកគ្គតាចេតសិក**

☞ វចនត្ថរបស់ឯកគ្គតាចេតសិក នានាលម្ពណវិក្ខេបាភាវេន ឯកំ អារម្មណំ អគ្គំ ឥមិស្សាតិ ឯកគ្គំ ចិត្តំ តស្ស ភាវោ ឯកគ្គតា ប្រែថា ចិត្តដែលឈ្មោះថា ឯកគ្គៈដោយអត្ថថា មានអារម្មណ៍តែមួយ ព្រោះមិនមានសេចក្តី រាយមាយទៅ ក្នុង អារម្មណ៍ផ្សេងៗ ។

ភាវៈនៃចិត្តមានអារម្មណ៍តែមួយនោះឈ្មោះថា ឯកគ្គតា ។ ឯកគ្គតាចេតសិកជាធម្មជាតិស្ងប់មិន

រាយមាយមិនអណ្តែអណ្តូង ទៅក្នុងអារម្មណ៍ផ្សេងៗឡើយ

ហើយញុំាងសម្បយុត្តធមិដែលកើតព្រមជាមួយនោះឯងឱ្យ

តាំងនៅក្នុងអារម្មណ៍តែមួយជាមួយគ្នា ។

-

## លក្ខណាទិចតុក្ករបស់ឯកគ្គតាចេតសិក

-លក្ខណៈរបស់ឯកគ្គតាចេតសិក

☞ អវិក្ខេបលក្ខណា មានការមិនរវើរវាយ មិនឃ្លេងឃ្លោងជាលក្ខណៈ ។

-កិច្ចរបស់ឯកគ្គតាចេតសិក

☞ សហជាតានំ សម្បិណ្ឌន រសា មានការប្រមូលសហជាតធម៌មករួមគ្នាជាកិច្ច

-ផល ឬ អាការៈប្រាកដរបស់ឯកគ្គតាចេតសិក

☞ឧបសមបច្ចុប្បដ្ឋានា មានការចូលទៅស្ងប់ជាផល ។

-ហេតុ ឬបទដ្ឋាន របស់ឯកគ្គតាចេតសិក

☞ សុខបទដ្ឋានា មានសុខវេទនាជាហេតុជិត ។

**៦-ជីវិតិន្ទ្រិយចេតសិក**

☞ វចនត្ថរបស់ជីវិតិន្ទ្រិយចេតសិក ជីវន្តិ តេន សម្បយុត្តធម្មាតិ ជីវិតំ តទេវ សហជាតានុបាលនេ អធិបច្ចយោ តេន

ឥន្ទ្រិយន្តិ ជីវិតិន្ទ្រិយំ ប្រែថា ធម្មជាតិដែលមានឈ្មោះថាជីវិតព្រោះមានវចនត្ថថាជាគ្រឿងតំរង់នៅនៃសម្បយុត្តធម៌គឺ

ជីវិតនោះឯងជាធំក្នុងការអនុបាលនូវសហជាតធម្មព្រោះនោះទើបឈ្មោះថា ជីវិតិន្ទ្រិយ ។ ជីវិតិន្ទ្រិយចេតសិកនេះជា

ធម្មជាតរក្សាអនុបាលនូវសម្បយុត្តធម៌គឺធ្វើឱ្យសម្បយុត្តធម៌នោះតាំងនៅ

និងប្រព្រឹត្តទៅបានតាមសភាពដ៏សមគួររបស់

ខ្លួន ។

## លក្ខណាទិចតុក្ករបស់ជីវិតិន្ទ្រិយចេតសិក

-លក្ខណៈរបស់ជីវិតិន្ទ្រិយចេតសិក

☞ សហជាតានំអនុបាលនលក្ខណំ មានការតាមតែរក្សានូវសហជាតធម៌

ដូចជាទឹកចិញ្ចឹមផ្កាជាលក្ខណៈ ។

-កិច្ចរបស់ជីវិតិន្ទ្រិយចេតសិក

☞ តេសំបវត្តនរសំ មានការញ៉ាំងសម្បយុត្តធម៌ឱ្យប្រព្រឹត្តទៅជាកិច្ច ។

-ផល ឬ អាការៈប្រាកដរបស់ជីវិតិន្ទ្រិយចេតសិក

-

☞ តេសញ្ញេវ ថបនបច្ចុប្បដ្ឋានំ មានការតំរង់នៅបាននៃសហជាតធម៌នោះជាអាការៈប្រាកដ ។

-ហេតុ ឬ បទដ្ឋានរបស់ជីវិតិន្ទ្រិយចេតសិក

☞ សេសក្ខន្ធត្តយបទដ្ឋានំ មាននាមក្ខន្ធ ៣ គឺវេទនា សញ្ញា វិញ្ញាណដែលសេសជាហេតុជិត ។

**៧-មនសិការចេតសិក**

☞ វចនត្ថរបស់មនសិការចេតសិក មនសិ ការោ មនសិការោ ប្រែថា

ធម្មជាតិដែលបានឈ្មោះមនសិការព្រោះមាន

វចនត្ថថា ការធ្វើទុកក្នុងចិត្ត ។

មនសិការចេតសិកនេះជាធម្មជាតិនាំសម្បយុត្តធម៌សំដៅកាន់អារម្មណ៍ ។

## លក្ខណាទិចតុក្ករបស់មនសិការចេតសិក

-លក្ខណៈរបស់មនសិការចេតសិក

☞ សារណលក្ខណោ មានការធ្វើឱ្យសម្បយុត្តធម៌ស្ទុះទៅជាលក្ខណៈ ។

-កិច្ចរបស់មនសិការចេតសិក

☞ សម្បយុត្តានំ អារម្មណេ សំយោជនរសោ

មានកិរិយាញ៉ាំងសម្បយុត្តធម៌ឱ្យប្រកបក្នុងអារម្មណ៍ជាកិច្ច ។

-ផល ឬ អាការៈប្រាកដរបស់មនសិការចេតសិក

☞ អារម្មណាភិមុខីភាវបច្ចុប្បដ្ឋានោ

មានការធ្វើឱ្យសម្បយុត្តធម៌តំរង់ឆ្ពោះទៅមុខទល់នឹងអារម្មណ៍ជាផល ។

-ហេតុ ឬ បទដ្ឋានរបស់មនសិការចេតសិក

☞ អារម្មណបទដ្ឋាន មានអារម្មណ៍ជាហេតុជិត ។

មនសិការៈនេះដូចគ្នានិងសតិដោយផលគឺអាការៈប្រាកដរបស់សតិក៏ទៅប្រទល់និងអារម្មណ៍ដោយអំណាចមិនភ្លេចភ្លាំង

ចំនែកមនសិការៈគឺប្រទល់និងអារម្មណ៍ដោយការធ្វើទុកក្រសោក ចង់ទុក ។

មនសិការៈមានលក្ខណៈដូចជានាយកសារថី ញាក់សេះឱ្យស្ទុះទៅ ។

អំពីមនសិការៈ ៣យ៉ាង

-

☞វិថីបដិបាទកមនសិការ

បានដល់មនសិការៈដែលធ្វើឱ្យវិថីចិត្តកើតគឺបញ្ចទ្វារាវជ្ជនចិត្តជាអនន្តរប្បច្ច័យ ឱ្យ ចក្ខុវិញ្ញាណជាដើមកើត ។

☞ ជវនបដិបាទកមនសិការ

បានដល់មនសិការៈដែលធ្វើជវនចិត្តឱ្យកើតគឺមនោទ្វារាវជ្ជនចិត្តជាអនន្តរប្បច្ច័យឱ្យជវនចិត្តកើតឡើង ។

☞ អារម្មណបដិបាទកមនសិការ

បានដល់មនសិការៈចេតសិកដែលធ្វើឱ្យអារម្មណ៍ប្រាកដបើគ្មានមនសិការៈចេតសិកទេ អារម្មណ៍ក៏រមែងមិនប្រាកដដែរ ។

ក្នុងសៀវភៅច្បាប់ខ្លះថា មនសិការៈ ខទី១ និង ខទី២ បានដល់យោនិសោមនសិការៈ ជួនកាលលោកក៏ថាបានដល់ អយោនិសោមនសិការៈ ផងដែរ ។

ចេតនា និង មនសិការៈ

ចេតសិកទាំង ២នេះមានសភាពប្រហែលគ្នាប៉ុន្តែមានដូចគ្នាទេគឺ ៖-

ក-ចេតនា

មាននាទីដាស់តឿននូវសម្បយុត្តធម៌ដែលកើតព្រមជាមួយខ្លួនឱ្យធ្វើកិច្ចរបស់ខ្លួនរៀងៗខ្លួន ។

ខ-មនសិការៈ ឋានៈនាទីនាំនូវសម្បយុត្តធម៌ដែលកើតឡើងព្រមជាមួយខ្លួនឱ្យតំរង់ឆ្ពោះទៅ ។ចេតសិកទាំង ៧ដួងនេះគឺ

ផស្ស វេទនា សញ្ញា ចេតនា ឯកគ្គតា ជីវិតិន្ទ្រិយ មនសិការ រមែងប្រកបជាមួយចិត្តគ្រប់ដួងទាំងអស់ពីព្រោះ សភាព នៃចិត្តនេះកើតឡើងគឺដើម្បីដឹងនូវអារម្មណ៍បាននោះ ក៏ព្រោះមកអំពី ផស្សៈ ធ្វើកិច្ចប៉ះខ្ទប់អារម្មណ៍ វេទនា ជាធម្មជាតិនូវសោយរសរបស់អារម្មណ៍ សញ្ញា ធ្វើកិច្ចគឺចងចាំនូវអារម្មណ៍ ចេតនា គឺធ្វើកិច្ចចាត់ចែងឱ្យសំរេច ឯកគ្គតា ជាធម្មជាតិ

មានអារម្មណ៍តែមួយព្រមទាំងញ៉ាំងសម្បយុត្តធម៌ដែលកើតរួមជាមួយ

ឱ្យតាំងនៅក្នុងអារម្មណ៍តែមួយជាមួយគ្នាផង

ជីវិតិន្ទ្រិយ៍ ជាសភាវៈសំរាប់ថែរក្សាអនុបាលសម្បយុត្តធម៌ឱ្យប្រព្រឹត្តទៅមនសិការ គឺធ្វើអារម្មណ៍ទុកក្នុងចិត្តនេះឯង ។

-

ដូច្នេះប្រសិនណាបើចេតសិកទាំង ៧ដូងនេះមិនកើតឡើងទេ ចិត្តក៏ រមែងកើតមិនបាន ដោយហេតុនេះហើយចេតសិក ៧

ដូងនេះទើបបានឈ្មោះថា សព្វចិត្តសាធារណចេតសិក ។

ការចែកសព្វចិត្តសាធារណចេតសិកដោយន័យផ្សេងៗ

១-ការចែកដោយចំណែកខន្ធគឺ វេទនាចេតសិក ជាវេទនាខន្ធ

សញ្ញាចេតសិក ជាសញ្ញាខន្ធ

ចេតសិក ៥ទៀតគឺ ផស្ស ចេតនា ឯកគ្គតា ជីវិតិន្ទ្រិយ មនសិការ ជាសង្ខារក្ខន្ធ ។

២-ការចែកដោយចំណែកជាតិគឺ ចេតសិក ៦ វៀរ វេទនាចេញ មានជាតិ ៤ សុខ ទុក្ខ មានជាតិជាវិបាក

ទោមនស្សវេទនាមានជាតិជាអកុសល

សោមនស្សវេទនា និង ឧបេក្ខាវេទនា មានជាតិ ៤ ។

៣-ការចែកដោយចំណែកទ្វារគឺ ចេតសិកទាំង ៦ វៀរតែវេទនា គឺកើតបានក្នុងទ្វារទាំង ៦

សុខវេទនា និង ទុក្ខវេទនា គឺកើតតាមកាយទ្វារឬទ្វារកាយ

ទោមនស្សវេទនា គឺកើតបានទាំង ៦ទ្វារ

សោមនស្សវេទនា និង ឧបេក្ខាវេទនាគឺកើតបានទាំង ៦ទ្វារនិងវិមុត្តិទ្វារ ។

៤-ការចែកដោយចំណែកនៃអារម្មណ៍គឺចេតសិកទាំង ៦ដឹងបានអារម្មណ៍ ៦ វៀរតែវេទនាចេតសិកគឺ

សុខវេទនា និងទុក្ខវេទនាគឺដឹងផោដ្ឋព្វារម្មណ៍

សោមនស្សវេទនា ទោមនស្សវេទនា និងឧបេក្ខាវេទនាដឹងបានអារម្មណ៍ទាំង ៦ ។

៥-ការចែកចំណែកដោយភូមិគឺចេតសិកទាំង ៦កើតបាន ៣០ ( វៀរ អសញ្ញីសត្តាភូមិ)

សុខវេទនា និងទុក្ខវេទនា កើតបានក្នុងកាមភូមិ ១១

ទោមនស្សវេទនាកើតបានក្នុងកាមភូមិ ១១

សោមនស្សវេទនាកើតបានកាមភូមិ ១១រូបភូមិ ១៥និងកើតក្នុងលោកុត្តរភូមិ

-

ឧបេក្ខាវេទនាកើតបានក្នុងកាមភូមិ ១១រូបភូមិ ១៥អរូបភូមិ ៤និងក្នុងលោកុត្តរភូមិ ។

៦-ការចែកដោយចំណែកវត្ថុគឺ ចេតសិកទាំង ៦ អាស្រ័យបានវត្ថុ ៦

សុខវេទនានិងទុក្ខវេទនាអាស្រ័យបានតែកាយវត្ថុ

ទោមនស្សវេទនានិងសោមនស្សវេទនា អាស្រ័យបានតែហទយវត្ថុ

ឧបេក្ខាវេទនាអាស្រ័យបានវត្ថុ ៥វៀរតែកាយវត្ថុចេញ ។

៧-ការចែកដោយចំណែកហេតុគឺ ចេតសិកទាំង ៦ជា នហេតុក គឺមិនមែនជាហេតុ ។

៨-ការចែកដោយសោភណគឺ ចេតសិកទាំង ៦ ជាសោភណក៏មាន ជាអសោភណក៏មានគឺ ៖-

សុខវេទនា ទុក្ខវេទនា និងទោមនស្សវេទនាជាអសោភណ

សោមនស្សនិង ឧបេក្ខាសោភណក៏មាននិងជាអសោភណក៏មាន ។

៩-ការចែកដោយចំណែកជាលោកិយគឺ ចេតសិកទាំ ៦ជាលោកិយក៏មាន និងជាលោកុត្តរក៏មាន គឺ ៖-

សុខវេទនា ទុក្ខវេទនានិងទោមនស្សវេទនាជាលោកិយ

សោមនស្សវេទនានិងឧបេក្ខវេទនាជាលោកិយក៏មាននិងជាលោកុត្តរក៏មាន ។

## បកិណ្ណកចេតសិក

បកិណ្ណកចេតសិកគឺជាចេតសិកដែលច្របូកច្របល់បន្ទាប់បន្សំ មិនប្រកបជាមួយនិងចិត្តគ្រប់ដួងទាំងអស់ទេគឺ ប្រកបបានតែជាមួយនិងចិត្តដួងខ្លះដែលសមគួរដល់ការប្រកបតែប៉ុណ្ណោះ ។

បកិណ្ណកចេតសិកនេះមាន ៦ គឺ ៖-

**១-វិតក្កចេតសិក** មានការលើកចិត្តឡើងកាន់អារម្មណ៍ជាលក្ខណៈ

**២-វិចារចេតសិក** មានការពិចារណានូវអារម្មណ៍ ជាលក្ខណៈ

**៣-អធិមោក្ខចេតសិក** មានការសន្និដ្ឋានសម្រេចចិត្ត ជាលក្ខណៈ

**៤-វីរិយចេតសិក** មានការឧស្សាហ៍ ជាលក្ខណៈ

**៥-បីតិចេតសិក** មានកាពេញចិត្ត ជាលក្ខណៈ

**៦-ឆន្ទចេតសិក** មានសេចក្តីប៉ុនប៉ងនឹងធ្វើ ជាលក្ខណៈ

-

អធិប្បាយអំពីបកិណ្ណកចេតសិក

**១-វិតក្កចេតសិក**

☞ វចនត្ថរបស់វិត្តកចេតសិក *អារម្មណំ វិតក្កេតិ សម្បយុត្តធម្មេ អភិនិរោបេតីតិ វិតក្កោ*

ប្រែថាធម្មជាតិដែលបានឈ្មោះ

ថាវិតក្កព្រោះមានវចនត្ថថារមែងត្រិះរិះនូវអារម្មណ៍គឺថាលើកនូវសម្បយុត្តធម៌ឡើងកាន់អារម្មណ៍ ។

**លក្ខណាទិចតុករបស់វិតក្កចេតសិក**

-លក្ខណៈរបស់វិតក្កចេតសិក

☞ អារម្មណេ ចិត្តស្ស អភិនិរោបនលក្ខណោ មានការលើកនូវចិត្តឡើងកាន់អារម្មណ៍ជាលក្ខណៈ

-កិច្ចរបស់វិតក្កចេតសិក

☞ អាហននបរិយាហនរសោ មានការធ្វើឱ្យចិត្តខ្ទប់នូវអារម្មណ៍ជាមួយអារម្មណ៍ជារឿយ ៗជាកិច្ច

-ផល ឬអាការៈប្រាកដ របស់វិតក្កចេតសិក

☞ អារម្មណេ ចិត្តស្ស អានយបច្ចុប្បដ្ឋានោ មានចិត្តមកនៅក្នុងអារម្មណ៍ជាផល

-ហេតុ ឬបទដ្ឋាន របស់វិតក្កចេតសិក

☞ អាបាថវិសយបទដ្ឋានោ មានអារម្មណ៍ក្នុងវិថីជាហេតុជិត ។ ន័យមួយទៀតលោកសំដែងថា

☞ សេសក្ខន្ធត្តយបទដ្ឋានោ  មាននាមក្ខន្ធដ៏សេស៣ទៀតគឺ វេទនា សញ្ញា វិញ្ញាណ ជាហេតុជិត ។

**២-វិចារចេតសិក**

☞ វចនត្ថរបស់វិចារចេតសិក អារម្មណេ តេន ធម្មេន ចិត្តំ វិចារតីតិ វិចារោ

ប្រែថាធម្មជាតិដែលបានឈ្មោះថា វិចារៈ ព្រោះមានវចនត្ថថា

រមែងផ្គងនូវចិត្តទៅក្នុងអារម្មណ៍ដោយធម៌នោះ ។

**លក្ខណាទិចតុករបស់វិចារចេតសិក**

-លក្ខណៈរបស់វិចារចេតសិក

☞ អារម្មណានុមជ្ជនលក្ខណោ

មានការចូលទៅប្រនៀលគឺពិចារណានូវអារម្មណ៍ជារឿយ ៗជាលក្ខណៈ

-កិច្ចរបស់វិចារចេតសិក

-

☞ តត្ថ សហជាតានុយោជនរសោ

មានការតាមប្រកបនូវសហជាតធម៌ឱ្យនៅតែក្នុងអារម្មណ៍នោះជាកិច្ច

-ផល ឬអាការៈប្រាកដ របស់វិចារចេតសិក

☞ ចិត្តានុប្បពន្ធប្បច្ចុប្បដ្ឋានោ មានការតាមចងនូវចិត្តទុកក្នុងអារម្មណ៍ជាផល

-ហេតុ ឬបទដ្ឋាន របស់វិចារចេតសិក

☞ អារម្មណបទដ្ឋានោ មានអារម្មណ៍ជាហេតុជិត ។ន័យមួយទៀតលោកសំដែងថា

☞ សេសក្ខន្ធត្តយបទដ្ឋានោ មាននាមក្ខន្ធដ៏សេស ៣ទៀតគឺ វេទនា សញ្ញា វិញ្ញាណជាហេតុជិត ។

**៣៉អធិមោក្ខចេតសិក**

☞ វចនត្ថរបស់អធិមោក្ខចេតសិក អធិមុច្ចនំ អធិមោក្ខោ ប្រែថា

ធម្មជាតិដែលបានឈ្មោះថាអធិមោក្ខព្រោះមាន

វចនត្ថថាសេចក្តីបង្អោនចិត្តទៅ( ជឿ )។ អធិមោក្ខនេះអ្នកសិក្សាទាំងឡាយគប្បីឃើញថា

ដូចជាសរសរខឿន ព្រោះ

ការនឹងថ្កល់ក្នុងអារម្មណ៍ ជាកុសលក៏មាន ជាអកុសលក៏មាន ប្រសិនណាបើអធិមោក្ខនេះជា

បសាទាធិមោក្ខ គឺការ

បង្អោនចិត្តជឿដោយអំណាចនៃសេចក្តីជ្រះថ្លានោះទើបជាកុសលពិត ។

**លក្ខណាទិចតុក្ករបស់អធិមោក្ខចេតសិក**

៉លក្ខណៈរបស់អធិមោក្ខចេតសិក

☞ សន្និដ្ឋានលក្ខណោ មានការសន្និដ្ឋានជាលក្ខណៈ

-កិច្ចរបស់អធិមោក្ខចេតសិក

☞ អសំសប្បនរសោ មានការមិនឃ្លេងឃ្លោងជាកិច្ច

-ផល ឬអាការៈប្រាកដរបស់អធិមោក្ខចេតសិក

☞វិនិច្ឆយបច្ចុប្បដ្ឋានោ មានការកាត់សេចក្តីជាផល

-ហេតុឬបទដ្ឋាន របស់អធិមោក្ខចេតសិក

☞ សន្និដ្ឋេយ្យធម្មបទដ្ឋានោ មានហេតុដែលគប្បីសន្និដ្ឋានជាហេតុជិត ។

**៤៉វីរិយចេតសិក**

-

☞ វចនត្ថរបស់វីរិយចេតសិក វីរានំ ភាវោ កម្មំ វិធិនា ឥរយិតព្ពំ បវត្តេ តព្ពន្តិ វា វីរិយំ ឧស្សាហោ ប្រែថាធម្មជាតិដែល

បានឈ្មោះថាវីរិយចេតសិកព្រោះមានវចនត្ថថា ភាព ឬអំពើ នៃបុគ្គលអង់អាច

ឬថាធម្មជាតិដែលបុគ្គលគប្បីប្រព្រឹត្តទៅ

ដោយវិធីគឺកាទ្រទ្រង់ទុកយ៉ាងវិសេស បានដល់សេចក្តីឧស្សាហ៍ ។

## លក្ខណាទិចតុក្ករបស់វីរិយចេតសិក

-លក្ខណៈរបស់វីរិយចេតសិក

☞ ឧស្សាហនលក្ខណំ មានការអង់អាចហ៊ាន ប្រឹងប្រែង ព្យាយាមជាលក្ខណៈ

-កិច្ចរបស់វីរិយចេតសិក

☞ សហជាតានំ ឧបត្ថម្ភនរសំ មានការឧបត្ថម្ភជ្រោមជ្រែងនូវសហជាតធម៌ជាកិច្ច

-ផល ឬអាការៈប្រាកដ របស់វីរិយចេតសិក

☞ អសំសីទនភាវបច្ចុប្បដ្ឋានំ មានការមិនរាថយជាផល

-ហេតុ ឬបទដ្ឋាន របស់វីរិយចេតសិក

☞ សំវេគវត្ថុបទដ្ឋានំ មានសង្វេគវត្ថុជាហេតុជិត ។ ន័យមួយទៀតលោកសំដែងថា វីរិយារម្ភវត្ថុបទដ្ឋានំ មានវត្ថុដែល

គប្បីត្រូវប្រារព្ធនូវសេចក្តីព្យាយាមជាហេតុជិត ។

## សង្វេគវត្ថុមាន ៨ យ៉ាងគឺ

ហេតុដែលជាទីតាំធ្វើឱ្យសេចក្តីសង្វេកគឺការតក់ស្លុតនៃចិត្តកើតឡើង ឈ្មោះថា សង្វេគវត្ថុ មាន ៨ យ៉ាងគឺ ៖-

១-ការពិចារណាដល់ជាតិទុក្ខ

២-ការពិចារណាដល់ជរាទុក្ខ

៣- ការពិចារណាដល់ព្យាធិទុក្ខ

៤- ការពិចារណាដល់មរណទុក្ខ

៥- ការពិចារណាដល់អបាយិកទុក្ខ

៦- ការពិចារណាដល់អតីតវដ្តមូលទុក្ខ

៧- ការពិចារណាដល់អនាគតវដ្តមូលទុក្ខ

-

៨- ការពិចារណាដល់ទុក្ខក្នុងការស្វែងរកអាហារក្នុងបច្ចុប្បន្ននេះ ។

**៥_បីតិចេតសិក**

☞ វចនត្ថរបស់បីតិចេតសិកបិនយតិ កាយចិត្តំ តប្បេតិ វឌ្ឍេតីតិ វា បីតិ ប្រែថា ធម្មជាតិដែលបានឈ្មោះថា បីតិព្រោះ

មានវចនត្ថថា ញ៉ាំងកាយ និងចិត្តឱ្យឆ្អែត ឱ្យរីករាយ ឬថា ញ៉ាំងកាយនិងចិត្តឱ្យចំរើន ។

**លក្ខណាទិចតុករបស់បីតិចេតសិក**

-លក្ខណៈរបស់បីតិចេតសិក

☞ សម្បិយាយនលក្ខណា មានសភាពស្រស់ស្រាយសប្បាយពេញចិត្តជាលក្ខណៈ

-កិច្ចរបស់បីតិចេតសិក

☞ កាយចិត្តសម្បីណនរសា មានការធ្វើឱ្យកាយនិងចិត្តឆ្អែតជាកិច្ច

-ផល ឬអាការៈប្រាកដរបស់បីតិចេតសិក

☞ ឱទគ្យបច្ចុបដ្ឋានា មានការរីករាយត្រេកអរជាផល

-ហេតុ ឬបទដ្ឋានរបស់បីតិចេតសិក

☞ សេសខន្ធត្តយបទដ្ឋានា មាននាមក្ខន្ធដ៏សេស ៣ ទៀតគឺ វេទនា សញ្ញា វិញ្ញាណ ជាហេតុជិត ។

**បីតិមាន ៥ យ៉ាង**

បីតិនេះលោកបានសំដែងទុកនៅក្នុងអង្គរបស់បឋមឈានថាមាន ៥ យ៉ាងគឺ ៖-

១-ខុទ្ទកាបីតិ មានសភាពត្រេកអរបន្តិចបន្តួច ឬមានការចេញទឹកភ្នែក និងព្រឺរោមជាដើម ។

២-ខណិកាបីតិ

មានសភាពត្រេកអរចិត្តត្រឹមតែមួយជួរខណៈប្រៀបដូចជាផ្លេកបន្ទោរតែកើតឡើងញឹកញាប់ ។

៣-ឱក្កន្តិកាបីតិ

មានសភាពត្រេកអរចិត្តមួយស្របក់ហើយក៏បាត់ទៅប្រៀបដូចជាទឹករលកបោកច្រាំងហើយបែកទេ ។

៤-ឧព្វេង្គាបីតិ មានសភាពត្រេកអរចិត្តដ៏ខ្លាំងរហូតអណ្តែតខ្លួនឡើង ។

៥-ផរណាបីតិ មានសភាពត្រេកអរចិត្តជ្រួតជ្រាបពាសពេញសព្វកាយ ប្រៀបដូចជាសំឡីជប់ទឹក ។

**៦_ឆន្ទចេតសិក**

-

☞ វចនត្ថរបស់ឆន្ទចេតសិក ឆន្ទនំ ឆន្ទោ ប្រែថាធម្មជាតិដែលបានឈ្មោះថា ឆន្ទៈព្រោះមានវចនត្ថថា សេចក្តីគាប់ចិត្ត ។

ឆន្ទៈនេះបើនិយាយឱ្យចំគឺ សេចក្តីប៉ងប្រាថ្នា ក្នុងអារម្មណ៍ទាំងឡាយមានរូបារម្មណ៍ជាដើម ។ ឆន្ទៈគឺការប៉ុនប៉ងក្នុង អារម្មណ៍នោះឯង អ្នកសិក្សាទាំងឡាយគប្បីឃើញថា ដូចជាបុរសលូកដៃឈោងទៅដើម្បីចាប់កាន់នូវវត្ថុណាមួយដែរ ។

**លក្ខណាទិចតុក្ករបស់ឆន្ទចេតសិក**

-លក្ខណៈរបស់ឆន្ទចេតសិក

☞ កត្តុកម្យតាលក្ខណោ មានការចូលចិត្តគឺការប៉ុនប៉ងនឹងធ្វើជាលក្ខណៈ

-កិច្ចរបស់ឆន្ទចេតសិក

☞ អារម្មណបរិយេសនរសោ មានការស្វែងរកនូវអារម្មណ៍ជាកិច្ច

-ផល ឬអាការៈប្រាកដរបស់ឆន្ទចេតសិក

☞ អារម្មណេន អត្ថិកតាបច្ចុប្បដ្ឋានោ មានការប្រាថ្នាដោយអារម្មណ៍ដែលត្រូវការជាផល

-ហេតុ ឬបទដ្ឋានរបស់ឆន្ទចេតសិក

☞ អារម្មណបទដ្ឋានោ មានអារម្មណ៍ជាហេតុជិត ។

បណ្តាបកិណ្ណកចេតសិកទាំង ៦នេះជាសង្ខារក្ខន្ធកាលបើប្រកបនឹងចិត្តបែបណាក៏រមែងបានទៅជាសភាពបែប នោះ ដោយហេតុដូច្នេះហើយទើបឈ្មោះថា បកិណ្ណកចេតសិក ។

**បាលីសំរាប់សូត្ររាប់ឈ្មោះពួកអញ្ញសមានាចេតសិកទាំង ២ ពួក**

**ផស្សោ វេទនា សញ្ញា ចេតនា ឯកគ្គតា ជីវិតិន្ទ្រិយំ មនសិការោ ចេតិ សត្តិមេ ចេតសិកា សព្វចិត្ត- សាធារណា នាម ។ វិតក្កោ វិចារោ អធិមោក្ខោ វីរិយំ បីតិ ឆន្ទោ ចេតិ ឆ ឥមេ ចេតសិកា បកិណ្ណកា នាម ។ ឯវមិមេ តេរស ចេតសិកា អញ្ញសមានាតិ វេទិតព្វា ។** ប្រែថា ចេតសិកទាំងឡាយ ៧នេះគឺ ផស្ស១ វេទនា១ សញ្ញា១ ចេតនា១ ឯកគ្គតា១ ជីវិតិន្ទ្រិយ៍១ មនសិការ១ ឈ្មោះថាសព្វចិត្តសាធារណៈ ។ (រីឯ) ចេតសិកទាំងឡាយ ៦នេះគឺ វិតក្កៈ១ វិចារៈ១ អធិមោក្ខៈ១ វីរិយៈ១ បីតិ១ ឆន្ទៈ១ ឈ្មោះថា បកិណ្ណកៈ ។ចេតសិក-

-

ទាំងឡាយ ១៣ នេះឯងអ្នកសិក្សាទាំងឡាយគប្បីជ្រាបថាឈ្មោះអញ្ញសមានា ( ដូច្នេះឯង ) ៕

## ចប់អញ្ញសមានាចេតសិកទាំង ១៣ ដោយសង្ខេប

## អកុសលចេតសិក

ពាក្យថា អកុសល គឺបានដល់ធម្មជាតិដែលជាទោស គឺធ្វើឱ្យសៅហ្មង ក្តៅក្រហាយវង្វេង ។ ដូច្នេះអកុសល

ចេតសិកបានដល់ចេតសិកផ្នែកខាងអាក្រក់ដែលជាទោស

កាលបើទៅប្រកបជាមួយនឹងចិត្តដួងណាហើយរមែងធ្វើឱ្យចិត្ត

ដួងនោះ មានទោសគឺសៅហ្មងក្តៅក្រហាយវង្វេងដែរ

ប៉ុន្តែអកុសលចេតសិកនេះប្រកបបានតែជាមួយនឹងអកុសលចិត្ត

១២ ដួងតែប៉ុណ្ណោះ ។ អកុសលចេតសិកមាន ១៤ ដួង ចែកចេញជា ៥ ន័យ ឬ ៥ ពួកដូចខាងក្រោម ៖-

**១-មោចតុកៈ** មាន ៤ គឺ

**១-មោហចេតសិក** មានការមិនដឹងនូវសភាវៈតាមសេចក្តីពិតជាលក្ខណៈ

**២-អហិរិកចេតសិក** មានការមិនខ្មើម ឬមិនខ្មាស់បាបជាលក្ខណៈ

**៣-អនោត្តប្បចេតសិក** មានការមិនខ្លាចតក់ស្លុតក្នុងបាបជាលក្ខណៈ

**៤-ឧទ្ធច្ចចេតសិក** មានការរវើរវាយមិនស្ងប់ជាលក្ខណៈ

**២-លោតិកៈ** មាន ៣ គឺ

**១-លោភចេតសិក** មានការជាប់ចំពាក់ក្នុងអារម្មណ៍ជាលក្ខណៈ

**២-ទិដ្ឋិចេតសិក** មានការប្រកាន់មិនត្រូវតាមទំនងជាលក្ខណៈ

**៣-មានចេតសិក** មានការលើកដំកើងខ្លួនជាលក្ខណៈ

**៣-ទោចតុកៈ** មាន ៤ គឺ

**១-ទោសចេតសិក** មានការប្រទុស្តក្នុងអារម្មណ៍ជាលក្ខណៈ

**២-ឥស្សាចេតសិក** មានការច្រណែនចំពោះសម្បត្តិរបស់អ្នកដ៏ទៃ

**៣-មច្ឆរិយចេតសិក** មានការកំណាញ់និងបិទបាំងសម្បត្តិរបស់ខ្លួនជាលក្ខណៈ

**៤-កុក្កុច្ចចេតសិក** មានកាក្តៅក្រហាយចិត្តជាខាងក្រោយជាលក្ខណៈ

**៤-ថីនទុកៈ** មាន ២ គឺ

-

**១‑ថីនចេតសិក** មានការខ្ជិលច្រអូសជាលក្ខណៈ

**២‑មិទ្ធចេតសិក** មានការមិនគួរដល់ការងារជាលក្ខណៈ

**៥‑ឯកវិចិកិច្ឆា** មាន ១ គឺ

☞ **វិចិកិច្ឆាចេតសិក** មានការសង្ស័យជាលក្ខណៈ

អធិប្បាយអំពីអកុសលចេតសិក

**១-មោហចេតសិក**

☞វចនត្ថរបស់មោហចេតសិក អារម្មណេ មុយ្ហតីតិ មោហោ អញ្ញាណំ ប្រែថា ធម្មជាតិដែលបានឈ្មោះថា មោហៈ

ព្រោះមានវចនត្ថថាវង្វេងក្នុងអារម្មណ៍ បានដល់ អញ្ញាណៈ គឺការមិនដឹង ដោយហេតុនោះទើបសត្វទាំងឡាយវមែង

វង្វេងដោយចេតសិកជាហេតុ ។

**លក្ខណាទិចតុករបស់មោហចេតសិក**

-លក្ខណៈរបស់មោហចេតសិក

☞ចិត្តស្ស អន្ធភាវលក្ខណោ មានភាពងងឹតនៃចិត្តជាលក្ខណៈ

-កិច្ចរបស់មោហចេតសិក

☞ អសម្បដិវេធរសោ មានការមិនចាក់ធ្លុះក្នុងសច្ចៈធមិជាកិច្ច

-ផល ឬ អាការៈប្រាកដរបស់មោហចេតសិក

☞ អសម្មាបដិបត្តិបច្ចុប្បដ្ឋានោ មានការបដិបត្តិមិនប្រពៃ ជាផល

-ហេតុ ឬ បទដ្ឋានរបស់មោហចេតសិក

☞ អយោនិសោមនសិការបទដ្ឋានោ មានការមិនធ្វើទុកក្នុងចិត្តដោយឧបាយនៃប្រាជ្ញា ជាហេតុជិត ។

ក្នុងច្បាប់ខ្លះលោកសំដែងថាមោហៈចេតសិកនេះមានលក្ខណាទិចតុក ម្យ៉ាងទៀតដូច្នេះគឺ

-លក្ខណៈរបស់មោហចេតសិក

☞អញ្ញាណលក្ខណោ មានការមិនដឹងជាលក្ខណៈ

-កិច្ចរបស់មោហចេតសិក

☞ អារម្មណសភាវច្ឆាទនរសោ មានការបិទបាំងនូវសភាវៈពិតនៃអារម្មណ៍ជាកិច្ច ។

-

-ផល ឬ អាការៈប្រាកដរបស់មោហចេតសិក

☞ អន្ធការបច្ចុប្បដ្ឋានោ មានការងងឹតគឺមិនដឹង ល្ងង់ខ្លៅជាផល ។

-ហេតុ ឬ បទដ្ឋានរបស់មោហចេតសិក

☞ អយោនិសោមនសិការបទដ្ឋានោ មានការមិនទុកក្នុងចិត្តដោយឧបាយនៃប្រាជ្ញាជាហេតុជិត ។

មោហៈនេះអ្នកសិក្សាទាំងឡាយគប្បីឃើញថាជាមូលហេតុនៃអកុសលទាំងពួងពោលគឺអវិជ្ជាបានដល់ការមិន ដឹងតាមសភាវៈធម៌ពិត ។

**២_អហិរិកចេតសិក**

☞ វចនត្ថរបស់អហិរិកចេតសិក នហិរិយតិ នលជ្ជិយតីតិ អហិរិកោ ប្រែថា

ធម្មជាតិដែលបានឈ្មោះថា អហិរិកៈព្រោះ

មានវចនត្ថថា មិនខ្មាស់ គឺថាមិនខ្ពើមនូវអំពើបាប ។

-លក្ខណៈរបស់អហិរិកចេតសិក

☞ អលជ្ជនលក្ខណំ មានការមិនខ្មាស់បាបជាលក្ខណៈ

-កិច្ចរបស់អហិរិកចេតសិក

☞ បាបានំ ករណរសំ មានការធ្វើនូវអំពើបាបជាកិច្ច

-ផល ឬ អាការៈប្រាកដរបស់អហិរិកចេតសិក

☞ អសំកោចនបច្ចុប្បដ្ឋានំ មានការមិនត្រឡប់ចាកបាបជាផល

-ហេតុ ឬបទដ្ឋានរបស់អហិរិកចេតសិក

☞ **អត្តាគារវបទដ្ឋានំ** មានការមិនគោរពខ្លួនឯងជាលក្ខណៈ ។

អហិរិកចេតសិកនេះលោកប្រៀបឧបមាដូចជាសត្វឆ្កែមិនខ្ពើមនូវគំរង់ យ៉ាងណាមិញ

អហិរិកៈនេះក៏ដូចគ្នាដែរ

គឺថាការមិនខ្មាស់និងសភាពមិនខ្ពើមនូវអំពើបាបទាំងឡាយរមែងមានព្រោះតែអហិរិក ។

**៣_អនោត្តប្បចេតសិក**

☞ វចនត្ថរបស់អនោត្តប្បចេតសិក ន ឧត្តប្បតីតិ អនោត្តប្បំ ប្រែថាធម្មជាតិដែលបានឈ្មោះថា

អនោត្តប្បៈ ព្រោះមាន

វចនត្ថថា មិនតក់ស្លុត មិនខ្លាចនូវអំពើបាប ។

**លក្ខណាទិចតុក្ករបស់អនោត្តប្បចេតសិក**

-

-លក្ខណៈរបស់អនោត្តប្បចេតសិក

☞ អសារជ្ជលក្ខណំ អនុត្តាសលក្ខណំ វា មានសភាពមិនខ្លាច ឬថាមិនតក់ស្លុតជាលក្ខណៈ

-កិច្ចរបស់អនោត្តប្បចេតសិក

☞ បាបានំ ករណរសំ មានការធ្វើនូវអំពើបាបជាកិច្ច

-ផល ឬអាការៈប្រាកដរបស់អនោត្តប្បចេតសិក

☞ អសង្កោចនបច្ចុប្បដ្ឋានំ មានការមិនត្រឡប់ចាកបាបជាផល

-ហេតុ ឬបទដ្ឋានរបស់អនោត្តប្បចេតសិក

☞ *បរទត្តាគារវបទដ្ឋានំ* មានការគោរពមិនកោតក្រែងចំពោះខ្លួនឯងនិងអ្នកដទៃជាហេតុជិត ។

**៤.ឧទ្ធច្ចចេតសិក**

☞ វចនត្ថរបស់ឧទ្ធច្ចចេតសិក ឧទ្ធតស្ស ភាវោ ឧទ្ធច្ចំ ប្រែថា ធម្មជាតិដែលបានឈ្មោះថា ឧទ្ធច្ចៈព្រោះមានវចនត្ថថា

ភាវៈនៃចិត្តដែលរវើរវាយមិនស្ងប់ ។

ឧទ្ធច្ចៈនេះមានសភាពឆ្លេឆ្លាទៅមកនៃចិត្តចំពោះអារម្មណ៍ទាំងឡាយ ។

**លក្ខណាទិចតុក្ករបស់ឧទ្ធច្ចចេតសិក**

-លក្ខណៈរបស់ឧទ្ធច្ចចេតសិក

☞ អវូបសមនលក្ខណំ មានការមិនចូលទៅស្ងប់ជាលក្ខណៈ

-កិច្ចរបស់ឧទ្ធច្ចចេតសិក

☞ អនវដ្ឋានរសំ មានការមិនតាំងនៅក្នុងអារម្មណ៍តែមួយជាកិច្ច

-ផល ឬអាការៈប្រាកដរបស់ឧទ្ធច្ចចេតសិក

☞ ភន្តត្តបច្ចុប្បដ្ឋានំ មានការវក់វីក្នុងអារម្មណ៍ជាផល

-ហេតុ ឬបទដ្ឋានរបស់ឧទ្ធច្ចចេតសិក

☞ អយោនិសោមនសិការបទដ្ឋានំ មានការមិនធ្វើទុកក្នុងចិត្តដោយឧបាយនៃប្រាជ្ញាជាហេតុជិត ។

អកុសលចេតសិកទាំង

៤ដួងគឺក្រុមមោចតុកៈនេះបានឈ្មោះថាអកុសលសាធារណចេតសិកព្រោះថាអកុសល-

-

ចេតសិក ៤ដួងនេះគឺ មោហៈ១ អហិរិកៈ១ អនោត្តប្បៈ១ ឧទ្ធច្ចៈ១គឺរមែងប្រកបជាមួយនិងអកុសលចិត្តគ្រប់ដួងមិនដូច អកុសលចេតសិកដ៏ទៃទៀតទេគឺថាអកុសលចេតសិកផ្សេងៗទៀតមិនឈ្មោះថាអកុសលសាធារណ ចេតសិកទេ ព្រោះថា ចេតសិកពួកនោះទៅប្រកបបានតែជាមួយនិងអកុសលចិត្តដួងខ្លះដែលសមគួរដល់ការប្រកបតែប៉ុណ្ណោះ ។

**៥-លោភចេតសិក**

☞ វចនត្ថរបស់លោភចេតសិក លុភ្ភតីតិ លោភោ ប្រែថា ធម្មជាតិដែលបានឈ្មោះថា លោភៈព្រោះមានវចនត្ថថា ប្រាថ្នាចង់បាន ។ លោភៈនេះរមែងប្រកបបានតែជាមួយនិងលោភមូលចិត្ត ៨ ដួងតែប៉ុណ្ណោះ ។

**លក្ខណាទិចតុក្ករបស់លោភចេតសិក**

-លក្ខណៈរបស់លោភចេតសិក

☞ អារម្មណគ្គហណលក្ខណោ មានការប្រកាន់មាំក្នុងអារម្មណ៍ជាលក្ខណៈ

-កិច្ចរបស់លោភចេតសិក

☞ អភិសង្គរសោ មានការជាប់ជំពាក់ក្នុងអារម្មណ៍ជាកិច្ច

-ផល ឬអាការៈប្រាកដរបស់លោភចេតសិក

☞ អបរិច្ចាគបច្ចុប្បដ្ឋានោ មានការមិនលះបង់ជាផល

-ហេតុ ឬបទដ្ឋានរបស់លោភចេតសិក

☞ សំយោជនីយធម្មេសុ អស្សាទទស្សនបទដ្ឋានោ មានការយល់ឃើញដោយសេចក្តីគាប់ចិត្តក្នុងធម៌ដែលជាអារម្មណ៍ របស់សំយោជនៈជាហេតុជិត ។

**៦-ទិដ្ឋិចេតសិក**

☞ វចនត្ថរបស់ទិដ្ឋិចេតសិកទស្សនំ ទិដ្ឋិ ប្រែថាធម្មជាតិដែលបានឈ្មោះថាទិដ្ឋិព្រោះមានវចនត្ថថា សេចក្តីយល់ឃើញ។

-

នៅក្នុងអភិធម្មត្ថភាវិនីដីកាសំដែងថា ឥទមេវ សច្ចំ មោឃមញ្ញន្តិ មិច្ឆា អភិនិវេសនលក្ខណទិដ្ឋិ ប្រែថា ទិដ្ឋិមានលក្ខណៈ ប្រកាន់ខុសថា សភាវៈនេះគឺកំណត់ប៉ុណ្ណេះ ថាជាសច្ចៈ ពាក្យដ៏ទៃគឺជាមោឃៈ ។ លោកបានពន្យល់ទុកដូច្នេះថា

១-សាមញ្ញទិដ្ឋិ គឺបានដល់ការយល់ឃើញខុសប្រាស់ចាកបរមត្ថ ថាសត្វ មនុស្ស ជាដើមគឺជា អត្តាទិដ្ឋិគឺទូទៅដល់តែពួក

បុថុជ្ជនមិនទូទៅដល់ព្រះអរិយបុគ្គលឡើយ ទើបបានឈ្មោះ សាមញ្ញទិដ្ឋិ ឬហៅថា សក្កាយទិដ្ឋិ ។

២-វិសេសទិដ្ឋិ គឺបានដល់ទិដ្ឋិទាំង៦២ វៀរតែ សក្កាយទិដ្ឋិចេញ ព្រោះទិដ្ឋិនេះប្រាកដដល់តែបុគ្គលពួកខ្លះ និងឱកាសខ្លះ។

ដូចជា និយតមិច្ឆាទិដ្ឋិ ៣ គឺ ៖-

☞ នត្ថិកទិដ្ឋិ មានការមិនជឿកម្ម និង វិបាករបស់កម្មជាដើម ។

☞ អហេតុកទិដ្ឋិ មានការយល់ឃើញថា សភាវៈធម៌ទាំងឡាយកើតឡើងដោយគ្មានហេតុ ។

☞ អកិរិយទិដ្ឋិ មានការយល់ឃើញថា

ការប្រព្រឹត្តដូចជាមិនបានប្រព្រឹត្តគឺថាអំពើដែលខ្លួនធ្វើហើយគ្មានផល ។

ចំណែកនៅក្នុងអដ្ឋសាលិនីអត្ថកថាធម្មសង្គណីបករណ៍អធិប្បាយឈ្មោះរបស់ទិដ្ឋិទុកដូច្នេះថា ៖-

១-ទិដ្ឋិមានឈ្មោះថា ទិដ្ឋិគតៈ គឺលោកពោលសំដៅយកដំណើរប្រព្រឹត្តទៅក្នុង ទិដ្ឋិទាំងឡាយ ៦២ យ៉ាង ។

២- ទិដ្ឋិមានឈ្មោះថា ទិដ្ឋិគហណៈ គឺលោកពោលសំដៅយកសេចក្តីប្រកាន់៧នេះគឺសត្វទាំងឡាយឆ្លងបានដោយលំបាក។

៣-ទិដ្ឋិមានឈ្មោះថា ទិដ្ឋិកន្តារៈ គឺសំដៅយកផ្លូវឆ្ងាយព្រោះថាសេចក្តីយល់ឃើញមានសភាពបែបនេះគួរឱ្យភ័យខ្លាច ។

៤-ទិដ្ឋិមានឈ្មោះថា វិសូកាយិកៈ គឺសំដៅយកចំរូង ព្រោះជាទំនាស់គឺបដិបក្ខជាមួយនិងសម្មាទិដ្ឋិ គឺសេចក្តីយល់ត្រូវ ។

៥-ទិដ្ឋិមានឈ្មោះថា វិប្ផន្ទិកៈ គឺសំដៅយក ការវិបត្តិព្រោះការប្រែប្រួល គ្រាខ្លះប្រកាន់ថាទៀង គ្រាខ្លះថាសូន្យ ។

៦-ទិដ្ឋិមានឈ្មោះថា សំយោជនៈ ព្រោះជាគ្រឿងចងរួបរិត ។

-

៧-ទិដ្ឋិមានឈ្មោះថា ទាខៈ ព្រោះការប្រកាន់មាំក្នុងអារម្មណ៍ ។

៨-ទិដ្ឋិមានឈ្មោះថា បតិដ្ឋាវាហៈ ព្រោះជាការបន្សាត់ទៅដ៏មានកំលាំង ។

៩-ទិដ្ឋិមានឈ្មោះថា អភិនិវេសនៈ ព្រោះការប្រកាន់ខ្លួននិងវត្ថុរបស់ខ្លួនថាជាសភាវៈទ្បេងទាត់ថិតថេរមាំមួន ។

១០-ទិដ្ឋិមានឈ្មោះថា កុម្មគ្គៈ ព្រោះជាផ្លូវអបាយដែលបណ្ឌិតតក់ស្លុតហើយស្អប់ខ្ពើម ។

១១-ទិដ្ឋិមានឈ្មោះថា បរាមាសៈ ព្រោះការស្ទាបអង្អែលគឺការកន្លងនូវសភាវៈពិតមានកាន់យកតាមប្រការដ៏ទៃវិញ ។

១២-ទិដ្ឋិមានឈ្មោះថា មិច្ឆាបថៈ គឺមិនមែនជាផ្លូវនៃសេចក្ដីពិត ។

១៣-ទិដ្ឋិមានឈ្មោះថា តិត្ថាយនៈ គឺជាអណ្ដូងដែល ជាទីអស្រ័យនិងជាទីកើតឡើងនៃអ្នកមានលទ្ធិដូចជាកំពង់ទឹក ។

១៤-ទិដ្ឋិមានឈ្មោះថា មិច្ឆត្តៈ ព្រោះជាសភាពនៃយល់ការខុស ។

១៥-ទិដ្ឋិមានឈ្មោះថា វិបរិយេសគ្គាហៈ ព្រោះការកាន់យកនូវសភាវៈដោយការប្រកាន់ខុស ។

## លក្ខណាទិចតុក្ករបស់ទិដ្ឋិចេតសិក

-លក្ខណៈរបស់ទិដ្ឋិចេតសិក

☞ អយោនិសោ អភិនិវេសលក្ខណា

មានការប្រកាន់ទុកដោយមិនមែនជាឧបាយនៃប្រាជ្ញាជាលក្ខណៈ

-កិច្ចរបស់ទិដ្ឋិចេតសិក

☞ បរាមាសរសា មានការស្ទាបអង្អែលជាកិច្ច

-ផល ឬអាការៈប្រាកដរបស់ទិដ្ឋិចេតសិក

☞ មិច្ឆាភិនិវេសបច្ចុប្បដ្ឋានា មានការប្រកាន់មាំក្នុងសេចក្ដីយល់ឃើញខុសជាផល

-ហេតុ ឬបទដ្ឋានរបស់ទិដ្ឋិចេតសិក

☞ អរិយានំ អទស្សនកាមតាទិបទដ្ឋានា មានការមិនចង់ឃើញនូវព្រះអរិយៈជាដើមជាហេតុជិត ។

### ៧_មានៈចេតសិក

☞ វចនត្ថរបស់មានៈចេតសិក *សេយ្យោហមស្មីតិ អទិនា មញ្ញតីតិ មានោ* ប្រែថា ធម្មជាតិដែលបានឈ្មោះថា មានៈ

-

ព្រោះមានវចនត្ថថា ការប្រកាន់គឺក្រអឺតក្រទម ដូចជាពាក្យថា អញជាបុគ្គលប្រសើរជាងគេជាដើម ។

## លក្ខណាទិចតុក្ករបស់មានចេតសិក

-លក្ខណៈរបស់មានៈចេតសិក

☞ ឧណ្ណតិលក្ខណោ មានការក្រអឺតជាលក្ខណៈ

-កិច្ចរបស់មានៈចេតសិក

☞ សម្បគ្គហរសោ មានការប្រកាន់ឬកជាកិច្ច

-ផល ឬអាការៈប្រាកដរបស់មានៈចេតសិក

☞ កេតុកម្យតាបច្ចុប្បដ្ឋានោ មានការប្រាថ្នាខ្ពស់ជាផល

-ហេតុ ឬបទដ្ឋានរបស់មានៈចេតសិក

☞ ទិដ្ឋិវិប្បយុត្តបទដ្ឋានោ មានលោភៈប្រាស់ចាកទិដ្ឋិជាហេតុជិត ។ មានៈនេះលោកចែកចេញជា ២យ៉ាងគឺ អាយាថាវមានៈ គឺមានៈដែលព្រះសោតាបន្នត្រូវលះ ១ និង

យាថាវមានៈគឺមានៈដែលព្រះអរហន្តលះ ១ ។

នៅក្នុងព្រះអភិធម្មបិដកវិភង្គបករណ៍លោកសំដែងថា មានៈនេះមាន ៣យ៉ាងគឺ ៖-

១-ការប្រកាន់ថា អញប្រសើជាងគេ

២-ការប្រកាន់ថា អញស្មើគេ

៣-ការប្រកាន់ថា អញថោកទាបជាងគេ ។

### ៨-ទោសចេតសិក

☞ វចនត្ថរបស់ទោសចេតសិក ទុស្សតីតិ ទោសោ ប្រែថា ធម្មជាតិដែលបានឈ្មោះថា ទោសៈ ព្រោះមានវចនត្ថថា

ប្រទុស្ត ។ នៅក្នុងវិសុទ្ធិមគ្គបករណ៍វិសេសលោកពន្យល់ថា ទុសន្តិ តេន សយំ វា ទុស្សតិ ទុសនមត្តមេវ វា តន្តិ ទោសោ

ប្រែថា ធម្មជាតិដែលបានឈ្មោះថា ប្រទុស្ត ព្រោះមានអត្ថថា ជាហេតុដែលប្រទុស្តក្នុងសត្វក្តី ប្រទុស្តចំពោះខ្លួនឯងក្តី

ក៏ត្រឹមតែការប្រទុស្តនោះឯង ឈ្មោះថា ទោសៈ ។ លោកឧបមាថា ទោសៈនេះអ្នកសិក្សាទាំងឡាយគប្បីឃើញថា ដូចជា

-

ទឹកមូត្រដែលឆ្អេះ លាយដោយថ្នាំពិសមិនគួរប៉ះពាល់ដោយប្រការផ្សេងៗឡើយ ។ ម្យ៉ាងទៀតទោសៈនេះលោកទុកដូច
ជាភ្លើងដែលបុគ្គលយកមកដុតខ្លួនឯង គឺថា
បើកើតមានក្នុងចិត្តបុគ្គលណាធ្វើឱ្យចិត្តបុគ្គលក្រហល់ក្រហាយ អន្ទះអន្ទែង។

## លក្ខណាទិចតុក្ករបស់ទោសចេតសិក

-លក្ខណៈរបស់ទោសចេតសិក

☞ចណ្ឌិកលក្ខណោ មានការកាចជាលក្ខណៈ

-កិច្ចរបស់ទោសចេតសិក

☞វិសប្បនរសោ មានការក្តៅក្រហាយជាកិច្ច ឬថា អត្តនោនិស្សយទហនរសោ មានការធ្វើឱ្យចិត្តខ្លួនឯងនិងអ្នកដ៏ទៃ
ក្តៅក្រហាយរោលរាលខ្លោចផ្សាជាកិច្ច

-ផល ឬអាការៈប្រាកដរបស់ទោសចេតសិក

☞ទុស្សនច្ចុបដ្ឋានោ មានការប្រទុស្តជាផល

-ហេតុ ឬបទដ្ឋានរបស់ទោសចេតសិក

☞អាឃាតវត្ថុបទដ្ឋានោ មានវត្ថុដែលជាទីតាំងនៃការចងគំនុំជាហេតុជិត ។

### ៩-ឥស្សាចេតសិក

☞វចនត្ថរបស់ឥស្សាចេតសិក ឥស្សតីតិ ឥស្សា ប្រែថា ធម្មជាតិដែលបានឈ្មោះឥស្សាព្រោះមានវចនត្ថថាច្រណែន ។

ឥស្សានេះ ជាសំយោជនៈ គឺជាគ្រឿងចងសត្វទុកក្នុងវដ្តៈព្រោះតែ ការឈ្នានីស ច្រណែន ប្រច័ណ្ឌ រារាំងមិនឱ្យអ្នកដ៏ទៃ
បាននូវលាភ សក្ការៈ សេចក្តីគោរព រាប់អាន និង ការបូជាជាដើម ។

## លក្ខណាទិចតុក្ករបស់ឥស្សាចេតសិក

-លក្ខណៈរបស់ឥស្សាចេតសិក

☞បរសម្បត្តីនំ ឧស្សូយនលក្ខណា មានការច្រណែននិងសម្បត្តិ ឬ
សេចក្តីល្អរបស់អ្នកដ៏ទៃជាលក្ខណៈ

-កិច្ចរបស់ឥស្សាចេតសិក

-

☞ តត្ថេវ អនធិរតិរសា មានការមិនត្រេកអរក្នុងសេចក្តីមានបានរបស់អ្នកដ៏ទៃជាកិច្ច

-ផល ឬអាការៈប្រាកដរបស់ឥស្សាចេតសិក

☞ តតោ វិមិខភាវបច្ចុបដ្ឋានា មានការងាករមុខចេញពីសម្បត្តិរបស់អ្នកដ៏ទៃជាផល ។

-ហេតុ ឬបទដ្ឋានរបស់ឥស្សាចេតសិក

☞ បរសម្បត្តិបទដ្ឋានា មានសម្បត្តិអ្នកដ៏ទៃជាហេតុជិត ។

**១០~មច្ឆរិយចេតសិក**

☞ វចនត្ថរបស់មច្ឆរិយចេតសិក មច្ឆេរស្ស ភាវោ ប្រែថា ធម្មជាតិដែលបានឈ្មោះថា មច្ឆរិយៈ ព្រោះមានវចនត្ថថា

ភាពនៃសេចក្តីកំណាញ់ ។

**លក្ខណាទិចតុករបស់មច្ឆរិយចេតសិក**

-លក្ខណៈរបស់មច្ឆរិយចេតសិក

☞ អត្តនោ សម្បត្តីនំ និគូហណលក្ខណំ មានការលាក់លៀមនូវសម្បត្តិរបស់ខ្លួនដែលបានហើយជាលក្ខណៈ

-កិច្ចរបស់មច្ឆរិយចេតសិក

☞ តាសំ យេវបរេហិ សាធារណភាវអក្ខនរសំ

មានការអត់ទ្រាំមិនបានក្នុងសម្បត្តិសាធារណៈដល់ជនដ៏ទៃជាកិច្ច

-ផល ឬអាការៈប្រាកដរបស់មច្ឆរិយចេតសិក

☞ សង្កោចនបច្ចុប្បដ្ឋានំ មានការធ្វើមុខក្រញូវជាផល

-ហេតុ ឬបទដ្ឋានរបស់មច្ឆរិយចេតសិក

☞ អត្តសម្បត្តិបទដ្ឋានំ មានសម្បត្តិខ្លួនជាហេតុជិត

**១១~កុក្កុច្ចចេតសិក**

☞ វចនត្ថរបស់កុក្កុច្ចៈចេតសិក កុកតស្ស ភាវោ បវត្តនិមិត្តំ កុក្កុច្ចំ ប្រែថា

ធម្មជាតិដែលបានឈ្មោះ កុក្កុច្ចៈ ព្រោះមាន

វចនត្ថថា ភាវៈ គឺ និមិត្តនៃការប្រព្រឹត្តទៅរបស់កម្មដែលបណ្ឌិតស្អប់ខ្ពើម ។ កុក្កុច្ចៈនេះគឺជាការកង្វល់នៃចិត្តមកអំពីការ

កើតឡើងនៃចិត្តុប្បាទដែលប្រារព្ធនូវកម្មគឺទុច្ចរិតដែលខ្លួនបានធ្វើហើយ
និងសុច្ចរិតដែលខ្លួនមិនបានធ្វើហើយ កម្មនេះឯង
ឈ្មោះថាកម្មដែលបណ្ឌិតស្អប់ខ្ពើម ។អ្នកសិក្សាទាំងឡាយគប្បីឃើញថា កុក្កុច្ចៈ នេះដូចជាទាសៈគឺជាអ្នកបំរើ ដែលមិន
ប្រព្រឹត្តទៅតាមទំនើងនៃចិត្តរបស់ខ្លួន ។

## លក្ខណាទិចតុករបស់កុក្កុច្ចចេតសិក

-លក្ខណៈរបស់កុក្កុច្ចៈចេតសិក

☞ *បច្ឆានុត្តាបនលក្ខណំ* មានការក្តៅក្រហាយចិត្តជាខាងក្រោយជាលក្ខណៈ

-កិច្ចរបស់កុក្កុច្ចៈចេតសិក

☞ កតាកតានុសោចនរសំ មានការសោកសៅជារឿយៗក្នុងអំពើបាបដែលខ្លួនបានធ្វើហើយ និងអំពើបុណ្យដែលខ្លួនមិន
ទាន់បានធ្វើជាកិច្ច

-ផល ឬអាការៈប្រាកដរបស់កុក្កុច្ចៈចេតសិក

☞វិប្បដិសារបច្ចុប្បដ្ឋានំ មានការស្តាយក្រោយជាផល

-ហេតុ ឬបទដ្ឋានរបស់កុក្កុច្ចៈចេតសិក

☞ កតាកតបទដ្ឋានំ មានបាបដែលបានធ្វើហើយ និងបុណ្យដែលមិនទាន់បានធ្វើជាហេតុជិត ។

**១២_ថីនចេតសិក**

☞ វចនត្ថរបស់ថីនចេតសិក *ថីនតា ថីនំ* ប្រែថា ធម្មជាតិដែលបានឈ្មោះថា ថីនៈព្រោះមានវចនត្ថថា សេចក្តីរួញរា ។
លោកអធិប្បាយទុកថា សភាពរួញរានៃចិត្តគឺធ្វើឱ្យចិត្តមិនគួរដល់នូវការងារនេះឯងឈ្មោះថា ថីនៈ ។

## លក្ខណាទិចតុករបស់ថីនចេតសិក

-លក្ខណៈរបស់ថីនចេតសិក

☞ អនុស្សហនលក្ខណំ មានការមិនអង់អាច មិនឧស្សាហ៍ជាក្នុងកុសលជាលក្ខណៈ

-កិច្ចរបស់ថីនចេតសិក

☞វីរិយវិនោទនរសំ មានការបន្ទោរបង់នូវសេចក្តីព្យាយាមចាកិច្ច

-

-ផល ឬអាការៈប្រាកដរបស់ថីនចេតសិក

☞ សំសីទនបច្ចុប្បដ្ឋានំ មានការរួញរាស្ទាក់ស្ទើនៃចិត្តជាផល

-ហេតុ ឬបទដ្ឋានរបស់ថីនចេតសិក

☞ អរតី វិជិម្ភតាទីសុ អយោនិសោមនសិការបទដ្ឋានំ មានការមិនធ្វើទុកក្នុងចិត្តដោយឧបាយនៃប្រាជ្ញាក្នុងការត្រេកអរ ក្នុងកុសលទាំងឡាយជាហេតុជិត ។

**១៣-មិទ្ធចេតសិក**

☞ វចនត្ថរបស់មិទ្ធៈចេតសិក មិជ្ឈនតា មិទ្ធំ ប្រែថាធម្មជាតិដែលបានឈ្មោះថាមិទ្ធៈ ព្រោះមានវចនត្ថថាភាពងោកងុយ នៃចិត្ត ។

**លក្ខណាទិចតុក្ករបស់មិទ្ធចេតសិក**

-លក្ខណៈរបស់មិទ្ធៈចេតសិក

☞ អកម្មញ្ញតាលក្ខណំ មានការមិនគួរគឺមិនរហ័សរហួនដល់ការងារជាលក្ខណៈ

-កិច្ចរបស់មិទ្ធៈចេតសិក

☞ឱនហនរសំ មានការបិទបាំងនូវសហជាតធម៌ជាកិច្ច

-ផល ឬអាការៈប្រាកដរបស់មិទ្ធៈចេតសិក

☞ លីនតាបច្ចុប្បដ្ឋានំ មានការងោកងុយរួញរាជាផល

ហេតុ ឬបទដ្ឋានរបស់មិទ្ធៈចេតសិក

☞ អរតី វិជិម្ភតាទីសុ អយោនិសោមនសិការបទដ្ឋានំ មានការមិនធ្វើទុកក្នុងចិត្តដោយឧបាយនៃប្រាជ្ញា ក្នុងការមិន ត្រេកអរក្នុងសភាពងោកងុយរួញរាជាដើមជាហេតុជិត ។ ថីនៈ និង មិទ្ធៈចេតសិកទាំង ២ នេះប្រកបតែជាមួយនិងចិត្តដែលជាសសង្ខារិក ៥ ដួងគឺ លោភមូលចិត្ត ៤ដួងនិងទោសមូលចិត្ត ១ដួង ។ ចេតសិកទាំង ពីរនេះកើតរួមជាមួយគ្នាជានិច្ចគឺ ថីនៈលោកប្រៀបដូចជាអណ្តាតភ្លើង មិទ្ធៈលោកទុកជាពន្លឺភ្លើង ។

**១៤-វិចិកិច្ឆាចេតសិក**

-

☞ វចនត្ថរបស់វិចិកិច្ឆាចេតសិកវិគតា ចិកិច្ឆាតិ វិចិកិច្ឆា ប្រែថា ធម្មជាតិដែលបានឈ្មោះថាវិចិកិច្ឆាព្រោះមានវចនត្ថថា មានសេចក្តីពិតប្រាកដប្រាសទៅហើយ ពោលគឺសេចក្តីសង្ស័យ សេចក្តីសង្ស័យនេះលោកសំដែងទុកថាមាន ៨គឺ សង្ស័យក្នុងព្រះពុទ្ធ១ ព្រះធម៌ ១ ព្រះសង្ឃ ១ សិក្ខា ១ ធម៌ជាអតីតៈ ១ ធម៌ជាអនាគត ១ ធម៌ជាអតីតៈនិងអនាគត១ និងក្នុងបដិច្ចសមុប្បាទធម៌១ វិចិកិច្ឆានេះជាធម្មជាតិមួយដែលអ្នកសិក្សាទាំងឡាយគប្បីឃើញថាជាធម្មជាតិដែលធ្វើនូវសេចក្តីអន្តរាយដល់ការបដិបត្តិ ។

## លក្ខណាទិចតុក្ករបស់វិចិកិច្ឆាចេតសិក

-លក្ខណៈរបស់វិចិកិច្ឆាចេតសិក

☞ សំសយនលក្ខណា មានការសង្ស័យជាលក្ខណៈ

-កិច្ចរបស់វិចិកិច្ឆាចេតសិក

☞ កម្បនរសា មានការឃ្លេងឃ្លោងក្នុងអារម្មណ៍ជាកិច្ច

-ផល ឬអាការៈប្រាកដរបស់វិចិកិច្ឆាចេតសិក

☞ អនិច្ឆយបច្ចុដ្ឋានា មានការមិនវិនិច្ឆ័យជាផល ឬថាអនេកសគាហបច្ចុប្បដ្ឋានា មានការមិនកាន់យកតែមួយជាផល ។

-ហេតុ ឬបទដ្ឋានរបស់វិចិកិច្ឆាចេតសិក

☞ អយោនិសោមនសិការបទដ្ឋានា មានការមិនធ្វើទុកក្នុងចិត្តដោយឧបាយនៃប្រាជ្ញាហេតុជិត ។

## បាលីសំរាប់សូត្ររាប់ឈ្មោះអកុសលចេតសិក

**មោហោ អហិរិកំ អនោត្តប្បំ ឧទ្ធច្ចំ លោភោ ទិដ្ឋិ មានោ ទោសោ ឥស្សា មច្ឆរិយំ កុក្កុច្ចំ ថីនំ មិទ្ធំ**

**វិចិកិច្ឆា ចេតិ ចុទ្ទសិមេ ចេតសិកា អកុសលា នាម** ប្រែថា ចេតសិកទាំងឡាយ ១៤នេះគឺ ទោសៈ១ អហិរិកៈ១ អនោត្តប្បៈ១ ឧទ្ធច្ចៈ១ លោភៈ១ ទិដ្ឋិ១ មានៈ១ ទោសៈ១ ឥស្សា១ មច្ឆរិយៈ១ កុក្កុច្ចៈ១ ថីនៈ១ មិទ្ធៈ១ វិចិកិច្ឆា១ ឈ្មោះថា អកុសលចេតសិក ។

-

## ចប់អកុសលចេតសិកទាំង ១៤ដោយសង្ខេប

## សោភណចេតសិក

សោភណចេតសិក ជាចេតសិកដែលល្អស្អាត ។កាលណាកើតរួមជាមួយនិងចិត្តណា ចិត្តនោះក៏ជាចិត្តល្អស្អាត
ហើយបានឈ្មោះថា សោភណចិត្ត ។ សោភណចេតសិកផ្សេងគ្នាអំពីអកុសលចេតសិក ព្រោះអកុសលចេតសិកកើតរួម
នឹងអកុសលចិត្ត ១២ដួងប៉ុណ្ណោះ ប៉ុន្តែសោភណចេតសិកវិញគឺកើតរួមជាមួយនឹងកុសលចិត្តក៏បាន កើតរួមនឹងកុសល-
វិបាកចិត្តក៏បាន កើតនឹងសោភណកិរិយាចិត្តក៏បាន ។ ដូច្នេះ សោភណចេតសិក ទើបកើតរួមជាមួយនឹង កាមាវចរកុសល
( មហាកុសល ) រូបាវចរកុសល អរូបាវចរកុសល លោកុត្តរកុសល កាមាវចរសហេតុកវិបាក ( មហាវិបាក )រូបាវចរវិបាក
អរូបាវចរវិបាក លោកុត្តរវិបាក កាមាវចរសហេតុកកិរិយា (មហាកិរិយា) រូបាវចរកិរិយា អរូបាវចរកិរិយា ។

សោភណចេតសិកមាន ២៥ ដួង កើតរួមជាមួយនឹងសោភណចិត្តតាមសមគួរដល់ប្រភេទនៃសោភណចេតសិក
ដោយហេតុនេះលោកចែកសោភណចេតសិកជា ៤ ពួកគឺ ៖-

**១-សោភណសាធារណចេតសិក** មាន ១៩ ដួងគឺ

**១-សទ្ធាចេតសិក** មានការជឿក្នុងកុសលជាលក្ខណៈ

**២-សតិចេតសិក** មានការរលឹកបានជាលក្ខណៈ

**៣-ហិរិចេតសិក** មានការខ្មាស់បាបជាលក្ខណៈ

**៤-ឱត្តប្បចេតសិក** មានការខ្លាចបាបជាលក្ខណៈ

**៥-អលោភចេតសិក** មានការមិនជាប់ជំពាក់ក្នុងអារម្មណ៍ជាលក្ខណៈ

**៦-អទោសចេតសិក** មានការមិនប្រទុស្តជាលក្ខណៈ

**៧-តត្រមជ្ឈត្តតាចេតសិក** មានការនាំចិត្តនិងចេតសិកទៅដោយស្មើជាលក្ខណៈ

**៨-កាយបស្សទ្ធិចេតសិក** មានការស្ងប់នាមក្ខន្ធ ៣ ជាលក្ខណៈ

-

**៩-ចិត្តបស្សទ្ធិចេតសិក** មានការស្ងប់ចិត្តជាលក្ខណៈ

**១០-កាយលហុតាចេតសិក** មានការស្ងប់ភាពធ្ងន់នៃនាមក្ខន្ធ ៣ ជាលក្ខណៈ

**១១-ចិត្តលហុតាចេតសិក** មានការស្ងប់ភាពធ្ងន់នៃចិត្តជាលក្ខណៈ

**១២-កាយមុទុតាចេតសិក** មានការស្ងប់ភាពរឹងនៃនាមក្ខន្ធ ៣ ជាលក្ខណៈ

**១៣-ចិត្តមុទុតាចេតសិក** មានការស្ងប់ភាពរឹងនៃចិត្តជាលក្ខណៈ

**១៤-កាយកម្មញ្ញតាចេតសិក** មានការស្ងប់ភាពដែលមិនគួរដល់ការងារនៃនាមក្ខន្ធ ៣ ជាលក្ខណៈ

**១៥-ចិត្តកម្មញ្ញតាចេតសិក**

មានការស្ងប់ភាពដែលមិនគួរដល់ការងារនៃចិត្តជាលក្ខណៈ

**១៦-កាយបាគុញ្ញតាចេតសិក** មានការស្ងប់ភាពឈឺចាប់នៃនាមក្ខន្ធ ៣ ជាលក្ខណៈ

**១៧-ចិត្តបាគុញ្ញតាចេតសិកិ** មានការស្ងប់ភាពឈឺចាប់នៃចិត្តជាលក្ខណៈ

**១៨-កាយុជុកតាចេតសិក** មានការស្មោះត្រង់នៃនាមក្ខន្ធ ៣ ជាលក្ខណៈ

**១៩-ចិត្តុជុកតាចេតសិក** មានការស្មោះត្រង់នៃចិត្តជាលក្ខណៈ

**២-វិរតិចេតសិក** មាន ៣ ដួងគឺ

**១-សម្មាវាចាចេតសិក**

មានការមិនល្មើសនូវវត្ថុដែលជាទីតាំងនៃវចីទុច្ចរិតជាលក្ខណៈ

**២-សម្មាកម្មន្តចេតសិក**

មានការមិនល្មើសនូវវត្ថុដែលជាទីតាំងនៃកាយទុច្ចរិតជាលក្ខណៈ

**៣-សម្មាអាជីវចេតសិក**

មានការមិនល្មើសនូវវត្ថុដែលជាទីតាំងនៃកាយទុច្ចរិតនិងវចីទុច្ចរិត ជាលក្ខណៈ

**៣-អប្បមញ្ញាចេតសិក** មាន ២ ដួងគឺ

**១-ករុណាចេតសិក** មានបំណងបំបាត់នូវសេចក្តីទុក្ខរបស់អ្នកដ៏ទៃជាលក្ខណៈ

**២-មុទិតាចេតសិក** មានការស្ងើចសរសើរនូវសម្បត្តិរបស់អ្នកដ៏ទៃជាលក្ខណៈ

**៤-បញ្ញិន្ទ្រិយចេតសិក** មាន ១ ដួងគឺ

**-បញ្ញាចេតសិក** មានការដឹងច្បាស់តាមសភាវៈធមិពិតជាលក្ខណៈ

-

អធិប្បាយអំពីសោភណចេតសិក

**១.សទ្ធាចេតសិក**

☞ វចនត្ថរបស់សទ្ធាចេតសិក សទ្ទហតីតិ សទ្ធា ប្រែថា ធម្មជាតិដែលបានឈ្មោះថា សទ្ធាព្រោះមានវចនត្ថថាមែងជឿ ជ្រះថ្លា ។សទ្ធានេះបានដល់ការជឿ ការជ្រះថ្លាក្នុងព្រះរតនៈត្រ័យទាំងឡាយមានព្រះពុទ្ធរតនៈជាដើម ឬថាការជឿក្នុងកម្ម និងផលរបស់កម្មជាដើម ពោលរួមមក គឺការជឿនូវហេតុនិងផលនៃហេតុ ។

**លក្ខណាទិចតុក្ករបស់សទ្ធាចេតសិក**

-លក្ខណៈរបស់សទ្ធាចេតសិក

☞ សទ្ទហនលក្ខណា មានការជឿ (ក្នុងកុសល) ជាលក្ខណៈ ឬថាឱកប្បនលក្ខណា មានការជឿមុតមាំជាលក្ខណៈ

ឬថា សម្បក្ខន្ទនលក្ខណា មានការស្ទុះទៅជាលក្ខណៈ

-កិច្ចរបស់សទ្ធាចេតសិក

☞ សម្បសាទនរសា មានការថ្លាស្អាតជាកិច្ច

-ផល ឬអាការៈប្រាកដរបស់សទ្ធាចេតសិក

☞ អកាលុស្សិយបច្ចុប្បដ្ឋានា មានការមិនកករល្អកជាផល

-ហេតុ ឬបទដ្ឋានរបស់សទ្ធាចេតសិក

☞ សទ្ធេយ្យវត្ថុបទដ្ឋានា មានវត្ថុជាទីតាំងនៃការជឿជាហេតុជិត ។

**២.សតិចេតសិក**

☞ វចនត្ថរបស់សតិចេតសិកសរណំ សតិ អសមោសោ ប្រែថា ធម្មជាតិដែលបានឈ្មោះថា សតិព្រោះមានវចនត្ថថា សេចក្តីរលឹកបាន ពោលគឺសេចក្តីមិនភ្លេចភ្លាំងមិនវង្វេង ។ ន័យមួយទៀតលោកថា សរន្តិ ឯតាយ សយំ វា សរតិ សរណមត្តមេវ វា ឯសា សតិ ប្រែថា បុគ្គលតែងរលឹកបាន ដោយធម្មជាតិនោះ ដូច្នេះធម្មជាតិនោះឈ្មោះថា សតិ ឬថា

-

ធម្មជាតិនោះ តែងរលឹកបានដោយខ្លួនឯងដូច្នោះ ធម្មជាតិនោះឈ្មោះថា សតិ ឬថា ធម្មជាតិនោះត្រឹមតែជាការរលឹក

ប៉ុណ្ណោះ ដូច្នោះ ធម្មជាតិនោះឈ្មោះថា សតិ ។

## លក្ខណាទិចតុក្ករបស់សតិចេតសិក

-លក្ខណៈរបស់សតិចេតសិក

☞ អបិលាបនលក្ខណា មានការរលឹកបានក្នុងអារម្មណ៍ជាលក្ខណៈ

-កិច្ចរបស់សតិចេតសិក

☞ អសម្មោហរសា មានការមិនវង្វេងជាកិច្ច

-ផល ឬអាការៈប្រាកដរបស់សតិចេតសិក

☞ អារក្ខបច្ចុប្បដ្ឋានា មានការរក្សានូវលក្ខណៈរបស់អារម្មណ៍ជាផល

-ហេតុ ឬបទដ្ឋានរបស់សតិចេតសិក

☞ ថិរសញ្ញាបទដ្ឋានា មានការចងចាំយ៉ាងមាំជាហេតុជិត ឬថា *កាយាទិសតិបទដ្ឋានា*

មានសតិប្បដ្ឋាន ៤មានកាយានុ

បស្សនាសតិប្បដ្ឋានជាដើមជាហេតុជិត ។

**៣~ហិរិចេតសិក**

☞ វចនត្ថរបស់ហិរិចេតសិកហិរិយតិ កាយទុច្ចរិតាទីហិ ជិគុច្ឆតីតិ ហិរិ ប្រែថា ធម្មជាតិដែលបានឈ្មោះថា ហិរិ ព្រោះ មានវចនត្ថថា តែងខ្មាស់គឺថាខ្ពើមចំពោះអំពើអាក្រក់ទាំងឡាយមានអំពើអាក្រក់ដោយកាយជាដើម ។

## លក្ខណាទិចតុក្ករបស់ហិរិចេតសិក

-លក្ខណៈរបស់ហិរិចេតសិក

☞ បាបតោ ជិគុច្ឆនលក្ខណា មានកាខ្ពើមចំពោះបាបជាលក្ខណៈ

-កិច្ចរបស់ហិរិចេតសិក

☞ បាបានំ អករណរសា មានការមិនធ្វើនូវអំពើបាបទាំងឡាយជាកិច្ច

-ផល ឬអាការៈប្រាកដរបស់ហិរិចេតសិក

☞ បាបតោ សង្កោចនបច្ចុប្បដ្ឋានា មានការមិនត្រឡប់មកធ្វើអំពើបាបទៀតជាផល

-ហេតុ ឬបទដ្ឋានរបស់ហិរិចេតសិក

-

☞ អត្តាគារវបទដ្ឋានា មានការគោរពខ្លួនឯងជាហេតុជិត ។

**៤-ឱត្តប្បចេតសិក**

☞ វចនត្ថរបស់ ឱត្តប្បៈចេតសិកភាយតិ កាយទុច្ចរិតាទីហិ ឱត្តប្បតីតិ ឱត្តប្បំ ប្រែថា ធម្មជាតិដែលបានឈ្មោះថា ឱត្តប្បៈ ព្រោះមាមវចនត្ថថា តែងភ័យខ្លាច គឺថាតក់ស្លុតចំពោះអំពើអាក្រក់ទាំងឡាយមានអំពើអាក្រក់ដោយ កាយ ជាដើម ។ ន័យមួយទៀតលោកថា ឱត្តប្បតិ ភាយតិ បាបតោតិ ឱត្តប្បំ ប្រែថា ភាវៈនៃធម្មជាតភ័យគឺថាខ្លាចបាប ។

**លក្ខណាទិចតុក្ករបស់ឱត្តប្បចេតសិក**

-លក្ខណៈរបស់ឱត្តប្បៈចេតសិក

☞ ឧត្តាសនលក្ខណំ មានការតក់ស្លុតចំពោះបាបជាលក្ខណៈ

-កិច្ចរបស់ឱត្តប្បៈចេតសិក

☞ បាបានំ អករណរសំ មានការមិនធ្វើនូវបាបទាំងឡាយជាកិច្ច

-ផល ឬអាការៈប្រាកដរបស់ឱត្តប្បៈចេតសិក

☞ បាបតោ សង្កោចនបច្ចុប្បដ្ឋានំ មានការមិនត្រឡប់មកធ្វើអំពើបាបទៀតជាផល

-ហេតុ ឬបទដ្ឋានរបស់ឱត្តប្បៈចេតសិក

☞ បរគារវបទដ្ឋានំ មានការគោរពអ្នកដ៏ទៃជាហេតុជិត ។

**៥-អលោភចេតសិក**

☞ វចនត្ថរបស់អលោភៈចេតសិក ន លុព្ភន្តិ តេន សយំ វា ន លុព្ភន្តិ អលុព្ភនំ មត្តមេវ តន្តិ អលោភោ ប្រែថា សត្វទាំង

ឡាយមិនលោភដោយធម្មជាតិនោះ ដូច្នេះធម្មជាតិនោះឈ្មោះថា អលោភៈ ឬថា ធម្មជាតិមិនលោភដោយខ្លួនឯង ធម្មជាតិនោះឈ្មោះ ថាអលោភៈ ឬថា ធម្មជាតិនោះមិនលោភតែប៉ុណ្ណោះឈ្មោះថា អលោភៈ ។ នៅក្នុងអដ្ឋសាលិនី

អត្ថកថាលោកសំដែងថា លោភបដិបក្ខតោ អលោភោ ប្រែថា ធម្មជាតិដែលបដិប័ក្ខនឹងលោភៈ ឈ្មោះថា អលោភៈ ។

**លក្ខណាទិចតុក្ករបស់លោភចេតសិក**

-លក្ខណៈរបស់អលោភៈចេតសិក

-

☞ អលគ្គភាវលក្ខណោ មានការមិនជាប់ជំពាក់ក្នុងអារម្មណ៍ជាលក្ខណៈ

-កិច្ចរបស់អលោភៈចេតសិក

☞ អបរិគ្គហរសោ មានការមិនហួងហែងជាកិច្ច

-ផល ឬអាការៈប្រាកដរបស់អលោភៈចេតសិក

☞ អនល្លីនភាវបច្ចុប្បដ្ឋនោ មានការមិនប្រកាន់ក្នុងអារម្មណ៍ជាផល

-ហេតុ ឬបទដ្ឋានរបស់អលោភៈចេតសិក

☞ *យោ*និសោមនសិការបទដ្ឋានោ មានការធ្វើទុកក្នុងចិត្តដោយឧបាយនៃប្រាជ្ញាជាហេតុជិត ។

**៦.អទោសចេតសិក**

☞ វចនត្ថរបស់អទោសៈចេតសិក*ទោសបដិបក្ខោ* អទោសោ ប្រែថា ធម្មជាតិដែលបានឈ្មោះថា អទោសៈព្រោះមាន

វចនត្ថថា បដិប័ក្ខដល់ទោសៈ ។

**លក្ខណាទិចតុករបស់អលោភចេតសិក**

-លក្ខណៈរបស់អទោសៈចេតសិក

☞ អចណ្ឌិកលក្ខណោ មានការមិនប្រទុស្តជាលក្ខណៈ

-កិច្ចរបស់អទោសៈចេតសិក

☞ អាឃាតវិនយរសោ មានការកំចាត់បង់នូវគំនុំជាកិច្ច

-ផល ឬអាការៈប្រាកដរបស់អទោសៈចេតសិក

☞ សោមភាវបច្ចុប្បដ្ឋានោ មានភាពត្រជាក់ជាផល

-ហេតុ ឬបទដ្ឋានរបស់អទោសៈចេតសិក

☞ យោនិសោមនសិការបទដ្ឋានោ មានការធ្វើទុកក្នុងចិត្តដោយឧបាយនៃប្រាជ្ញាជាហេតុជិត ។

**៧.តត្រមជ្ឈត្តតាចេតសិក**

☞ វចនត្ថរបស់តត្រមជ្ឈត្តតាចេតសិកតេសុ តេសុ ធម្មេសុ មជ្ឈត្តតា តត្រមជ្ឈត្តតា ប្រែថា ធម្មជាតិដែលបានឈ្មោះថា

តត្រមជ្ឈត្តតា ព្រោះមានវចនត្ថថា ភាពជាកណ្តាលក្នុងធម៌ទាំងឡាយនោះៗ ។

**លក្ខណាទិចតុករបស់តត្រមជ្ឈត្តតាចេតសិក**

-លក្ខណៈរបស់តត្រមជ្ឈត្តតាចេតសិក

-

☞ ចិត្តចេតសិកានំ សមវាហិតលក្ខណា មានការទ្រទ្រង់នូវចិត្តនិងចេតសិកឱ្យស្មើជាលក្ខណៈ

-កិច្ចរបស់តត្រមជ្ឈត្តតាចេតសិក

☞ ឩនាធិកតានិវារណរសា មានការហាមឃាត់នូវភាពមិនស្មើគ្នានៃសម្បយុត្តធម៌ជាកិច្ច

-ផល ឬអាការៈប្រាកដរបស់តត្រមជ្ឈត្តតាចេតសិក

☞ មជ្ឈត្តភាវបច្ចុប្បដ្ឋានា មានភាពជាកណ្តាលជាផល

-ហេតុ ឬបទដ្ឋានរបស់តត្រមជ្ឈត្តតាចេតសិក

☞ សម្បយុត្តានំ បទដ្ឋានា មានសម្បយុត្តធម៌ជាហេតុជិត ។

ចេតសិកតទៅនេះលោករៀងជាគូរ ហៅថា យុគលធម៌ ប៉ុន្តែដើម្បីភាពងាយស្រួលនៅក្នុងការសិក្សាខ្ញុំអ្នកសូម រៀបរៀងជាបែបរាយតាមលំដាប់លំដោយដូចតនេះ

**៨-កាយបស្សទ្ធិ**

☞ វចនត្ថរបស់កាយបស្សទ្ធិចេតសិកកាយស្ស បស្សម្ភនំ កាយបស្សទ្ធិ ប្រែថាធម្មជាតិដែលបានឈ្មោះថា កាយបស្សទ្ធិ ព្រោះមានវចនត្ថថា ការស្ងប់នៃកាយ ។

**លក្ខណាទិចតុក្ករបស់កាយបស្សទ្ធិចេតសិក**

-លក្ខណៈរបស់កាយបស្សទ្ធិចេតសិក

☞ កាយានំ វូបសមលក្ខណា មានការស្ងប់នាមខន្ធ ៣គឺ វេទនា សញ្ញា វិញ្ញាណជាលក្ខណៈ

-កិច្ចរបស់កាយបស្សទ្ធិចេតសិក

☞ កាយទរថនិម្មទ្ទនរសា មាការកំចាត់នូវសេចក្តីក្តៅក្រហាយនៃនាមក្ខន្ធជាកិច្ច

-ផល ឬអាការៈប្រាកដរបស់កាយបស្សទ្ធិចេតសិក

☞ កាយាបរិប្ផន្ទនសីតភាវបច្ចុប្បដ្ឋានា មានការមិនប្រែប្រួលនៃនាមក្ខន្ធជាផល

-ហេតុ ឬបទដ្ឋានរបស់កាយបស្សទ្ធិចេតសិក

☞ កាយចិត្តានំ បទដ្ឋានា មាននាមក្ខន្ធជាហេតុជិត ។

**៩-ចិត្តបស្សទ្ធិចេតសិក**

☞ វចនត្ថរបស់ចិត្តបស្សទ្ធិចេតសិក ចិត្តស្ស បស្សម្ភនំ ចិត្តបស្សទ្ធិ ប្រែថា ធម្មជាតិដែលបានឈ្មោះថា ចិត្តបស្សទ្ធិ ព្រោះ

-

មានវចនត្ថថា ការស្ងប់នៃចិត្ត ។

**លក្ខណាទិចតុក្ករបស់ចិត្តបស្សទ្ធិចេតសិក**

-លក្ខណៈរបស់ចិត្តបស្សទ្ធិចេតសិក

☞ចិត្តវូបសមលក្ខណា មានការស្ងប់ចិត្តជាលក្ខណៈ

-កិច្ចរបស់ចិត្តបស្សទ្ធិចេតសិក

☞ចិត្តទរថនិម្មទ្ទនរសា មានការកំចាត់នូភាពក្តៅក្រហាយនៃចិត្តនិងចេតសិកជាកិច្ច

-ផល ឬអាការៈប្រាកដរបស់ចិត្តបស្សទ្ធិចេតសិក

☞ចិត្តាបរិប្ផន្ទនសីតភាវបច្ចុប្បដ្ឋានា មានភាពត្រជាក់មិនប្រែប្រួលនៃចិត្ត និងចេតសិកជាផល

-ហេតុ ឬបទដ្ឋានរបស់ចិត្តបស្សទ្ធិចេតសិក

☞ចិត្តចេតសិកបទដ្ឋានា មានចិត្តនិងចេតសិកជាហេតុជិត ។

**១០.កាយលហុតាចេតសិក**

☞វចនត្ថរបស់កាយលហុតាចេតសិកកាយស្ស លហុភាវោ កាយលហុតា ប្រែថា ធម្មជាតិដែលបានឈ្មោះថា កាយលហុតា ព្រោះមានវចនត្ថថា ភាពស្រាលនៃកាយ ។

**លក្ខណាទិចតុក្ករបស់កាយលហុតាចេតសិក**

-លក្ខណៈរបស់កាយលហុតាចេតសិក

☞កាយគរុភាវវូបសមលក្ខណា មានការស្ងប់នូវភាពធ្ងន់នៃនាមខន្ធ ៣គឺ វេទនា សញ្ញា វិញ្ញាណជាលក្ខណៈ

-កិច្ចរបស់កាយលហុតាចេតសិក

☞កាយគរុភាវនិម្មទ្ទនរសា មានការកំចាត់នូវភាពធ្ងន់នៃនាមខន្ធជាកិច្ច

-ផល ឬអាការៈប្រាកដរបស់កាយលហុតាចេតសិក

☞កាយាទន្ធតា បច្ចុបទដ្ឋានា មានការរហ័សរហួននៃ នាមក្ខន្ធជាផល

-ហេតុ ឬបទដ្ឋានរបស់កាយលហុតាចេតសិក

☞កាយបទដ្ឋាន មាននាមក្ខន្ធជាហេតុជិត ។

**១១.ចិត្តលហុតាចេតសិក**

☞វចនត្ថរបស់ចិត្តលហុតាចេតសិក *ចិត្តស្ស លហុភាវោ ចិត្តលហុតា* ប្រែថា ធម្មជាតិដែលបានឈ្មោះ ចិត្តលហុតា ព្រោះ

-

មានវចនត្ថថា ភាពស្រាលនៃចិត្ត ។

## លក្ខណាទិចតុក្ករបស់ចិត្តលហុតាចេតសិក

-លក្ខណៈរបស់ចិត្តលហុតាចេតសិក

☞ចិត្តគរុភាវវូបសមលក្ខណា មានការស្ងប់នូវភាពធ្ងន់នៃចិត្តនិងចេតសិកជាលក្ខណៈ

-កិច្ចរបស់ចិត្តលហុតាចេតសិក

☞ចិត្តគរុភាវនិម្មទ្ទនរសា មានការកំចាត់នូវភាពធ្ងន់នៃចិត្តនិងចេតសិកជាកិច្ច

-ផល ឬអាការៈប្រាកដរបស់ចិត្តលហុតាចេតសិក

☞ចិត្តាទន្ធតាបច្ចុប្បដ្ឋានា មានការរហ័សរហួននៃចិត្តនិងចេតសិកជាផល

-ហេតុ ឬបទដ្ឋានរបស់ចិត្តលហុតាចេតសិក

☞ចិត្តបទដ្ឋានា មានចិត្តនិងចេតសិកជាហេតុជិត ។

**១២.កាយមុទុតាចេតសិក**

☞វចនត្ថរបស់កាយមុទុតាចេតសិកកាយស្ស មុទុភាវោ កាយមុទុតា ប្រែថា ធម្មជាតិដែលបានឈ្មោះថា កាយមុទុតា

ព្រោះមានវចនត្ថថា ភាពទន់ភ្លន់នៃកាយ ។

## លក្ខណាទិចតុក្ករបស់កាយមុទុតាចេតសិក

-លក្ខណៈរបស់កាយមុទុតាចេតសិក

☞កាយថម្ភវូបសមលក្ខណា មានការស្ងប់នូវភាពរឹងត្អឹងនៃកាយជាលក្ខណៈ

-កិច្ចរបស់កាយមុទុតាចេតសិក

☞កាយថម្ភនិម្មទ្ទនរសា មានការកំចាត់នូវភាពរឹងត្អឹងនៃកាយជាកិច្ច

-ផល ឬអាការៈប្រាកដរបស់កាយមុទុតាចេតសិក

☞អប្បដិឃាតបច្ចុប្បដ្ឋានា មានការមិនចង្អៀតចង្អល់ មិនក្រោធ មិនអាឃាតជាផល

-ហេតុ ឬបទដ្ឋានរបស់កាយមុទុតាចេតសិក

☞កាយចិត្តបទដ្ឋានា មាននាមខន្ធ ៤ ជាហេតុជិត ។

**១៣.ចិត្តមុទុតាចេតសិក**

☞វចនត្ថរបស់ចិត្តមុទុតាចេតសិក*ចិត្តស្ស* មុទុភាវោ ចិត្តមុទុតា ប្រែថា ធម្មជាតិដែលបានឈ្មោះថា ចិត្តមុទុតាព្រោះ

-

មានវចនត្ថថា ភាពទន់ភ្លន់នៃចិត្ត ។

**លក្ខណាទិចតុក្ករបស់ចិត្តមុទុតាចេតសិក**

-លក្ខណៈរបស់ចិត្តមុទុតាចេតសិក

☞ ចិត្តថម្ភវូបសមលក្ខណា មានការស្ងប់ភាពរឹងថ្មឹងនៃចិត្តជាលក្ខណៈ

-កិច្ចរបស់ចិត្តមុទុតាចេតសិក

☞ *ចិត្តថម្ភនិម្មទ្ទនរសា* មានការកំចាត់នូវភាពរឹងថ្មឹងចិត្តជាកិច្ច

-ផល ឬអាការៈប្រាកដរបស់ចិត្តមុទុតាចេតសិក

☞ អប្បដិឃាតបច្ចុប្បដ្ឋានា មានការមិនចង្អៀតចង្អល់ ( មិនចងអាឃាត ) ជាកិច្ច

-ហេតុ ឬបទដ្ឋានរបស់ចិត្តមុទុតាចេតសិក

☞ ចិត្តបទដ្ឋានា មានចិត្តជាបទដ្ឋាន ។

**១៤-កាយកម្មញ្ញតាចេតសិក**

☞ វចនត្ថរបស់កាយកម្មញ្ញតាចេតសិកកាយស្ស កម្មញ្ញភាវោ កាយកម្មញ្ញតា ប្រែថា ធម្មជាតិដែលបានឈ្មោះថា

កាយកម្មញ្ញតា ព្រោះមានវចនត្ថថា ភាពដែលគួរដល់ការងារនៃកាយ ។

**លក្ខណាទិចតុក្ករបស់កាយកម្មញ្ញតាចេតសិក**

-លក្ខណៈរបស់កាយកម្មញ្ញតាចេតសិក

☞ កាយាកម្មញ្ញភាវវូបសមលក្ខណា

មានការស្ងប់នូវភាពមិនគួរដល់នូវការងារនៃកាយជាលក្ខណៈ

-កិច្ចរបស់កាយកម្មញ្ញតាចេតសិក

☞ កាយាកម្មញ្ញភាវនិម្មទ្ទនរសា មានការកំចាត់បង់នូវភាពមិនគួរដល់ការងារជាកិច្ច

-ផល ឬអាការៈប្រាកដរបស់កាយកម្មញ្ញតាចេតសិក

☞ កាយាករណសម្បត្តិបច្ចុប្បដ្ឋានា មានការសមគួរដល់ព្រមក្នុងការធ្វើនៃកាយជាផល

-ហេតុ ឬបទដ្ឋានរបស់កាយកម្មញ្ញតាចេតសិក

☞ កាយបទដ្ឋានា មានកាយជាហេតុជិត ។

**១៥-ចិត្តកម្មញ្ញតាចេតសិក**

-

☞ វចនត្ថរបស់ចិត្តកម្មញ្ញតាចេតសិក *ចិត្តស្ស កម្មញ្ញភាវោ ចិត្តកម្មញ្ញតា* ប្រែថា

ធម្មជាតិដែលបានឈ្មោះថា ចិត្តកម្ម

ញ្ញតា ព្រោះមានវចនត្ថថា ភាពដែលគួរដល់ការងារនៃចិត្ត ។

**លក្ខណាទិចតុក្ករបស់ចិត្តកម្មញ្ញតាចេតសិក**

-លក្ខណៈរបស់ចិត្តកម្មញ្ញតាចេតសិក

☞ ចិត្តាកម្មញ្ញភាវវូបសមលក្ខណា មានការស្ងប់នូវភាពមិនគួរដល់ការងារនៃចិត្តជាលក្ខណៈ

-កិច្ចរបស់ចិត្តកម្មញ្ញតាចេតសិក

☞ ចិត្តាកម្មញ្ញភាវនិម្មទ្ទនរសា មានការកំចាត់បង់នូវភាពមិនគួរដល់ការងារនៃចិត្តជាកិច្ច

-ផល ឬអាការៈប្រាកដរបស់ចិត្តកម្មញ្ញតាចេតសិក

☞ ចិត្តារម្មណករណសម្បត្តិបច្ចុប្បដ្ឋានា

មានការដល់ព្រមក្នុងការធ្វើនៃចិត្តមានអារម្មណ៍សមគួរដល់ការងារជាផល

-ហេតុ ឬបទដ្ឋានរបស់ចិត្តកម្មញ្ញតាចេតសិក

☞ ចិត្តបទដ្ឋានា មាននាមខន្ធ ៤ ជាហេតុជិត ។

**១៦-កាយបាគុញ្ញតាចេតសិក**

☞ វចនត្ថរបស់កាយបាគុញ្ញតាចេតសិកកាយស្ស បាគុញ្ញភាវោ កាយបាគុញ្ញតា ប្រែថា

ធម្មជាតិដែលបានឈ្មោះថា

កាយបាគុញ្ញតា ព្រោះមានវចនត្ថថា ភាពឈ្លាសស្រួលស្រាលនៃកាយ ។

**លក្ខណាទិចតុក្ករបស់កាយបាគុញ្ញតាចេតសិក**

-លក្ខណៈរបស់ចិត្តកម្មញ្ញតាចេតសិក

☞ កាយគេលញ្ញវូបសមលក្ខណា មានការស្ងប់នូវការអាពាធនៃកាយជាលក្ខណៈ

-កិច្ចរបស់ចិត្តកម្មញ្ញតាចេតសិក

☞ កាយគេលញ្ញនិម្មទ្ទនរសា មានការកំចាត់បង់នូវការអាពាធនៃកាយជាកិច្ច

-ផល ឬអាការៈប្រាកដរបស់ចិត្តកម្មញ្ញតាចេតសិក

☞ កាយនិរាទីនវបច្ចុប្បដ្ឋានា មានការប្រាសចាកនូវទោសនៃកាយជាផល

-ហេតុ ឬបទដ្ឋានរបស់ចិត្តកម្មញ្ញតាចេតសិក

☞ កាយបទដ្ឋានា មានកាយជាហេតុជិត ។

-

**១៧. ចិត្តបាគុញ្ញតាចេតសិក**

☞ វចនត្ថរបស់ចិត្តបាគុញ្ញតាចេតសិកចិត្តស្ស បាគុញ្ញភាវោ ចិត្តបាគុញ្ញតា ប្រែថា ធម្មជាតិដែលបានឈ្មោះ ចិត្តបាគុញ្ញតា ព្រោះមានវចនត្ថថា ភាពឈ្លាសស្រួលស្រាលនៃកាយ ។

**លក្ខណាទិចតុករបស់ចិត្តបាគុញ្ញតាចេតសិក**

-លក្ខណៈរបស់ចិត្តកម្មញ្ញតាចេតសិក

☞ ចិត្តគេលញ្ញរូបសមលក្ខណា មានការស្ងប់នូវភាពអាពាធនៃចិត្តជាលក្ខណៈ

-កិច្ចរបស់ចិត្តកម្មញ្ញតាចេតសិក

☞ ចិត្តគេលញ្ញនិម្មទ្ទនរសា មានការកំចាត់បង់នូវភាពអាពាធនៃចិត្តជាកិច្ច

-ផល ឬអាការៈប្រាកដរបស់ចិត្តកម្មញ្ញតាចេតសិក

☞ ចិត្តនិរាទីវបច្ចុប្បដ្ឋានា មានការប្រាសចាកនូវទោសនៃចិត្តជាផល

-ហេតុ ឬបទដ្ឋានរបស់ចិត្តកម្មញ្ញតាចេតសិក

☞ ចិត្តបទដ្ឋានា មាននាមខន្ធ ៤ ជាហេតុជិត ។

**១៨. កាយុជុកតាចេតសិក**

☞ វចនត្ថរបស់កាយុជុកតាចេតសិកកាយស្ស ឧជុកភាវោ កាយុជុកតា ប្រែថា ធម្មជាតិដែលបានឈ្មោះថា កាយុជុកតា

ព្រោះមានវចនត្ថថា ភាពស្មោះត្រង់នៃកាយ ។

**លក្ខណាទិចតុករបស់កាយុជុកតាចេតសិក**

-លក្ខណៈរបស់ចិត្តកម្មញ្ញតាចេតសិក

☞ កាយុជុកភាវលក្ខណា មានភាពស្មោះត្រង់នៃកាយជាលក្ខណៈ

-កិច្ចរបស់ចិត្តកម្មញ្ញតាចេតសិក

☞ កាយកុដិលភាវនិម្មទ្ទនរសា មានការកំចាត់បង់នូវភាពវៀចវេរនៃកាយជាកិច្ច

-ផល ឬអាការៈប្រាកដរបស់ចិត្តកម្មញ្ញតាចេតសិក

☞ កាយាជិម្ហតា បច្ចុប្បដ្ឋានា មានភាពស្មោះត្រង់នៃកាយជាផល

-ហេតុ ឬបទដ្ឋានរបស់ចិត្តកម្មញ្ញតាចេតសិក

☞ កាយបទដ្ឋានា មានកាយជាហេតុជិត ។

**១៩. ចិត្តុជុកតាចេតសិក**

-

☞ វចនត្ថរបស់ចិត្តុជុកតាចេតសិកចិត្តស្ស ឧជុកភាវោ ចិត្តុជុកតា ប្រែថា ធម្មជាតិដែលបានឈ្មោះថា ចិត្តុជុកតា ព្រោះ មានវចនត្ថថា ភាពស្មោះត្រង់នៃកាយ ។

**លក្ខណាទិចតុក្ករបស់ចិត្តុជុកតាចេតសិក**

-លក្ខណៈរបស់ចិត្តុជុកតាចេតសិក

☞ ចិត្តុជុកភាវលក្ខណា មានភាពស្មោះត្រង់នៃចិត្តជាលក្ខណៈ

-កិច្ចរបស់ចិត្តុជុកតាចេតសិក

☞ ចិត្តកុដិលភាវនិម្មទ្ទនរសា មានការកំចាត់បង់នូវភាពវៀចវេរនៃចិត្តជាកិច្ច

-ផល ឬអាការៈប្រាកដរបស់ចិត្តុជុកតាចេតសិក

☞ ចិត្តាជិម្ហតា បច្ចុប្បដ្ឋានា មានភាពស្មោះត្រង់នៃចិត្តជាផល

-ហេតុ ឬបទដ្ឋានរបស់ចិត្តុជុកតាចេតសិក

☞ ចិត្តបទដ្ឋានា មាននាមខន្ធ ៤ ជាហេតុជិត ។

**បាលីសំរាប់សូត្ររាប់ឈ្មោះសោភណសាធារណចេតសិក ១៩**

**សទ្ធា សតិ ហិរិ ឱត្តប្បំ អលោភោ អទោសោ តត្រមជ្ឈត្តតា កាយបស្សទ្ធិ ចិត្តបស្សទ្ធិ កាយលហុតា ចិត្តលហុតា កាយមុទុតា ចិត្តមុទុតា កាយកម្មញ្ញតា ចិត្តកម្មញ្ញតា កាយបាគុញ្ញតា ចិត្តបាគុញ្ញតា កាយុជុកតា ចិត្តុជុកតា ចេតិ ឯកូនវីសតីមេ ចេតសិកា សោភណសាធារណា នាម** ប្រែថា ចេតសិកទាំងឡាយ ១៩ នេះគឺ សទ្ធា១ សតិ១ ហិរិ១ ឱត្តប្ប១ អលោភៈ១ អទោសៈ១ តត្រមជ្ឈត្តតា១កាយបស្សទ្ធិ១ ចិត្តបស្សទ្ធិ១ កាយលហុតា១ ចិត្តលហុតា១ កាយមុទុតា១ ចិត្តមុទុតា១ កាយកម្មញ្ញតា១ ចិត្តកម្មញ្ញតា១ កាយបាគុញ្ញតា១ ចិត្តបាគុញ្ញតា១ កាយុជុកតា១ ចិត្តុជុកតា១ ឈ្មោះថា សោភណសាធារណ ។

អធិប្បាយអំពីវិរតិចេតសិក

**១.សម្មាវាចាចេតសិក**

-

☞ វចនត្ថរបស់សម្មាវាចាចេតសិក *សម្មាវទន្តិ ឯតាយាតិ សម្មាវាចា* ប្រែថា ធម្មជាតិដែលបានឈ្មោះថា សម្មាវាចា ព្រោះមានវចនត្ថថា ជាគ្រឿងពោលដោយប្រពៃនៃសត្វទាំងឡាយ ។ ចេតសិកនេះគឺសំដៅដល់ការតាំងចិត្តមិនពោលនូវអំពើអាក្រក់ដោយផ្លូវវាចា ពោលគឺ វចីទុច្ចរិតទាំង ៤ គឺ

១-ការមិនពោលពាក្យកុហក

២-ការមិននិយាយញុះញង់

៣-ការមិននិយាយពាក្យអាក្រក់ គ្រោតគ្រាត

៤-ការមិននិយាយពាក្យឥតប្រយោជន៍ ។

## លក្ខណាទិចតុក្ករបស់សម្មាវាចាចេតសិក

-លក្ខណៈរបស់សម្មាវាចាចេតសិក

☞ វចីទុច្ចរិតវត្ថូនំ អវីតិក្កមលក្ខណា មានការមិនល្មើសនូវវត្ថុដែលជាទីតាំងនៃវចីទុច្ចរិតជាលក្ខណៈ

-កិច្ចរបស់សម្មាវាចាចេតសិក

☞ វចីទុច្ចរិតវត្ថុតោ សង្កោចនរសា  មានការប្រាសចាកអំពីវត្ថុដែលជាទីតាំងនៃវចីទុច្ចរិតជាកិច្ច

-ផល ឬអាការៈប្រាកដរបស់សម្មាវាចាចេតសិក

☞ តស្ស អក្រិយបច្ចុប្បដ្ឋានា មានការមិនប្រព្រឹត្តនូវវចីទុច្ចរិតនោះជាផល

-ហេតុ ឬបទដ្ឋានរបស់សម្មាវាចាចេតសិក

☞ សទ្ធាហិរោត្តប្បាប្បិច្ឆតាទិគុណបទដ្ឋានា មានគុណគឺ សទ្ធា ហិរិ ឱត្តប្បៈ និងសេចក្តីប្រាថ្នាតិចជាដើមជាហេតុជិត ។

## ២_សម្មាកម្មន្តចេតសិក

☞ វចនត្ថរបស់សម្មាកម្មន្តៈចេតសិកសម្មា បវត្តោ កម្មន្តោ សម្មាកម្មន្តោ ប្រែថា ធម្មជាតិដែលបានឈ្មោះថា សម្មាកម្មន្តៈព្រោះមានវចនត្ថថា ការងារដែលប្រព្រឹត្តទៅដោយប្រពៃនៃសត្វទាំងឡាយ ។ ចេតសិកនេះគឺសំដៅដល់-ចេតនានៃការតាំងចិត្តវៀរចាកនូវអំពើអាក្រក់ដោយកាយពោលគឺ កាយទុច្ចរិតទាំង ៣ គឺ

១-មិនសម្លាប់សត្វ

-

២-ការមិនលួច

៣-កាមិនប្រព្រឹត្តខុសក្នុងកាមទាំងឡាយ ។

**លក្ខណាទិចតុករបស់សម្មាកម្មន្តចេតសិក**

-លក្ខណៈរបស់សម្មាកម្មន្តៈចេតសិក

☞ កាយទុច្ចរិតវត្ថុនំ អវីតិក្កមលក្ខណោ

មានការមិនល្មើសកន្លងនូវវត្ថុដែលជាទីតាំងនៃកាយទុច្ចរិតជាលក្ខណៈ

-កិច្ចរបស់សម្មាកម្មន្តៈចេតសិក

☞ កាយទុច្ចរិតវត្ថុតោ សង្កោចនរសោ

មានការប្រាសចាកនូវវត្ថុដែលជាទីតាំងនៃកាយទុច្ចរិតជាកិច្ច

-ផល ឬអាការៈប្រាកដរបស់សម្មាកម្មន្តៈចេតសិក

☞ តស្ស អក្រិយបច្ចុប្បដ្ឋានោ មានការមិនប្រព្រឹត្តនូវកាយទុច្ចរិតនោះជាផល

-ហេតុ ឬបទដ្ឋានរបស់សម្មាកម្មន្តៈចេតសិក

☞ សទ្ធាហិរោត្តប្បាប្បិច្ឆតាទិគុណបទដ្ឋានោ មានគុណគឺ សទ្ធា ហិរិ ឱត្តប្បៈ សេចក្តីប្រាថ្នាតិចជាដើមជាហេតុជិត ។

**៣-សម្មាអាជីវចេតសិក**

☞ វចនត្ថរបស់សម្មាអាជីវៈចេតសិក សម្មា អាជីវន្តិ ឯតេនាតិ សម្មាអាជីវោ ប្រែថា ជាគ្រឿងទ្រទ្រង់មុខរបរដោយ

ប្រពៃនៃសត្វទាំងឡាយ ។ ចេតសិកនេះគឺបានដល់ការវៀរចាកការចិញ្ចឹមជីវិតខុសពោលគឺ មិច្ឆាជីវៈ ។ សម្មាអាជីវៈ-

មាន ៧ យ៉ាងគឺ

១-វៀរចាកកាយទុច្ចរិត ៣

២-វៀរចាកវចីទុច្ចរិត ៤ ។

**លក្ខណាទិចតុករបស់សម្មាអាជីវចេតសិក**

-លក្ខណៈរបស់សម្មាអាជីវៈចេតសិក

☞ តិវិធកាយទុច្ចរិតចតុព្វិធវចីទុច្ចរិតវត្ថូនំ អវីតិក្កលក្ខណោ

មានការមិនល្មើសកន្លងនូវវត្ថុដែលជាទីតាំងនៃកាយទុច្ចរិត

-

៣ និង វចីទុច្ចរិត ៤ជាលក្ខណៈ

-កិច្ចរបស់សម្មាអាជីវៈចេតសិក

☞ *តេសំ វត្ថុតោ សង្កោចនរសោ* មានការវៀរចាកនូវវត្ថុជាទីតាំងនៃកាយទុច្ចរិត ៣និងវចីទុច្ចរិត ៤ជាកិច្ច

-ផល ឬអាការៈប្រាកដរបស់សម្មាអាជីវៈចេតសិក

☞ តេសំ ទុច្ចរិតានំ អក្រិយបច្ចុប្បដ្ឋានោ មានការមិនធ្វើនូវទុច្ចរិតទាំងឡាយនោះជាផល

-ហេតុ ឬបទដ្ឋានរបស់សម្មាអាជីវៈចេតសិក

☞ សទ្ធាហិរោត្តប្បាប្បិច្ឆាទិគុណបទដ្ឋានោ មានគុណគឺ សទ្ធា ហិរិ ឱត្តប្បៈ សេចក្តីប្រាថ្នាតិចជាដើមជាហេតុជិត ។

## សេចក្តីពន្យល់

ធម្មជាតិដែលបានឈ្មោះថា វិរតិ នោះពោលគឺការមិនធ្វើនូវអំពើបាបទាំងពួង ។ វិរតិនោះមាន ៣ ប្រភេទគឺ

១-សម្បត្តវិរតិ

២-សមាទានវិរតិ

៣-សមុច្ឆេទវិរតិ

## សម្បត្តិវិរតិ

សម្បត្តិវិរតិបានដល់ការវៀរចាកបាបដោយអធ្យាស្រ័យរបស់ខ្លួន គឺជាអ្នកមិនសមាទានសិក្ខាបទទាំងឡាយ- បានពិចារណាដល់ការកើត និងការវិនាស និងពាហុសច្ចៈជាដើមរបស់ខ្លួនហើយក៏មិនប្រព្រឹត្តល្មើសនូវវត្ថុដែលជាទីតាំង នៃអំពើបាបដែលប្រាកដដល់ព្រមចំពោះមុខ ។

## សមាទានវិរតិ

សមាទានវិរតិបានដល់ការវៀរចាកបាបដោយសមាទាននូវសិក្ខាបទទាំងឡាយក្នុងវេលាសមាទាននោះ និងក្នុង កាលអស់មួយជីវិត តរៀងទៅរបស់ខ្លួន ។

## សមុច្ឆេទវិរតិ

-

សមុច្ឆេទវិរតិបានដល់ការវៀរចាកបាបដោយការកាត់ផ្តាច់ ដោយអរិយមគ្គ គឺវិរតិដែលសម្បយុត្តជាមួយ អរិយមគ្គ ។ កាលណាសមុច្ឆេទវិរតិកើតឡើងហើយ ចិត្តរបស់ព្រះអរិយបុគ្គលទាំងឡាយលោកមិនដែលមានគំនិតគិតថា យើងនឹងសម្លាប់សត្វ ឬបៀតបៀននូវសត្វទាំងឡាយឡើយ ។

**បាលីសំរាប់សូត្ររាប់ឈ្មោះវិរតិចេតសិក**

**សម្មាវាចា សម្មាកម្មន្តោ សម្មាអាជីវោ ចេតិ តិស្សោ វិរតិយោ នាម** ប្រែថា ចេតសិក ៣ គឺសម្មាវាចា១ សម្មាកម្មន្តៈ១ សម្មាអាជីវៈ១ ឈ្មោះថា វិរតិចេតសិក ។

អធិប្បាយអំពីអប្បមញ្ញាចេតសិក

☞ វចនត្ថរបស់អប្បមញ្ញាចេតសិក អប្បមានេសុ សត្តេសុ ភវតីតិ អប្បមញ្ញា ប្រែថា ធម្មជាតិដែលបានឈ្មោះថា អប្បមញ្ញា ព្រោះមានវចនត្ថថា រមែងផ្សាយទៅក្នុងសត្វទាំងឡាយមិនមានប្រមាណកំណត់ ។ មាន ២ គឺ ៈ-

**១.ករុណាចេតសិក**

☞ វចនត្ថរបស់ករុណាចេតសិក បរទុក្ខេ សតិ សាធូនំ ហទយកម្បនំ ករោតីតិ ករុណា ប្រែថា ធម្មជាតិដែលបានឈ្មោះ ថា ករុណា ព្រោះមានវចនត្ថថា រមែងធ្វើនូវសន្តានចិត្តរបស់សប្បុរសទាំងឡាយឱ្យញាប់ញ័រនៅស្ងៀមមិនបានគឺមានការ អាណិតអាសូរ កាលបើសត្វដ៏ទៃបាននូវសេចក្តីទុក្ខ ។ ឬថា កិណាតិ បរទុក្ខំ ហឹសតិ វិនាសេតីតិ ករុណា ប្រែថា ធម្មជាតិ ដែលបានឈ្មោះថា ករុណា ព្រោះមានវចនត្ថថា រមែងបៀត គឺថាបំបាត់នូវសេចក្តីទុក្ខរបស់សត្វដ៏ទៃ ។

**លក្ខណាទិចតុក្ករបស់ករុណាចេតសិក**

-លក្ខណៈរបស់ករុណាចេតសិក

-

☞ បរទុក្ខាបនយនាការប្បវត្តិលក្ខណា មានការប្រព្រឹត្តទៅនៃកាយ វាចា ចិត្តដើម្បីបំបាត់ទុក្ខរបស់អ្នកដ៏ទៃជាលក្ខណៈ

-កិច្ចរបស់ករុណាចេតសិក

☞ បរទុក្ខាសហនរសា មានការអត់ទ្រាំមិនបានទូវសេចក្តីទុក្ខរបស់សត្វជាកិច្ច

-ផល ឬអាការៈប្រាកដរបស់ករុណាចេតសិក

☞ អវិហឹសាបច្ចុប្បដ្ឋានា មានការមិនបៀតបៀនជាផល

-ហេតុ ឬបទដ្ឋានរបស់ករុណាចេតសិក

☞ ទុក្ខាភិភូតានំ អនាថភាវទស្សនបទដ្ឋានា មានការពិចារណាឃើញនូវបុគ្គលដែលធ្លាក់ក្នុងសេចក្តីទុក្ខគ្មាន

ទីពឹងជាហេតុជិត ។

**២-មុទិតាចេតសិក**

☞ វចនត្ថរបស់មុទិតាចេតសិក មោទន្តិ ឯតាយាតិ មុទិតា ប្រែថា បុគ្គលរមែងត្រេកអរីករាយក្នុងសេចក្តីសុខក្នុង សម្បត្តិគ្រប់គ្រាន់នៃអ្នកដ៏ទៃដូច្នេះធម្មជាតិនោះព្រោះហេតុនោះធម្មជាតិនោះឈ្មោះថា មុទិតា ។

**លក្ខណាទិចតុករបស់មុទិតាចេតសិក**

-លក្ខណៈរបស់មុទិតាចេតសិក

☞ បមោទនលក្ខណា មានការត្រេកអរក្នុងគុណគឺសេចក្តីល្អរបស់អ្នកដទៃជាលក្ខណៈ

-កិច្ចរបស់មុទិតាចេតសិក

☞ អនិស្សាយនរសា  មានការមិនច្រណែនជាកិច្ច

-ផល ឬអាការៈប្រាកដរបស់មុទិតាចេតសិក

☞ អរតិឃាតបច្ចុប្បដ្ឋានា មានការពិឃាតទំលាយនូវសេចក្តីច្រណែនជាផល

-ហេតុ ឬបទដ្ឋានរបស់មុទិតាចេតសិក

☞ បរសម្បត្តិទស្សនបទដ្ឋានា មានការឃើញនូវសេចក្តីចំរើនដោយគុណគឺសេចក្តីល្អរបស់អ្នកដ៏ទៃជាហេតុជិត ។

អធិប្បាយអំពីបញ្ញិន្ទ្រិយចេតសិក

**បញ្ញាចេតសិក**

-

☞វចនត្ថរបស់បញ្ញាចេតសិក បជានាតីតិ បញ្ញា ប្រែថា ធម្មជាតិដែលបានឈ្មោះថា បញ្ញាព្រោះមានវចនត្ថថា រមែងដឹងទូទៅ ។ បញ្ញានេះគឺលោកសំដៅយកការដឹងច្បាស់នូវអរិយសច្ចៈព្រោះអត្ថរបស់បញ្ញាស័ព្ទនេះគឺលោកសំដៅយកនូវការដឹងនូវសភាពប្រែប្រួលនៃសង្ខារធម៌ជាដើម ។

**លក្ខណាទិចតុក្ករបស់បញ្ញាចេតសិក**

-លក្ខណៈរបស់បញ្ញាចេតសិក

☞ធម្មសភាវប្បដិវេធលក្ខណា មានការចាក់ធ្លុះនូវសភាវធម៌ជាលក្ខណៈ

-កិច្ចរបស់បញ្ញាចេតសិក

☞សភាវបដិច្ឆាទនមោហន្ធការវិទ្ធំសនរសាមានការកំចាត់នូវភាពងងឹតគឺមោហៈចេញដែលបិទបាំងនូវសភាវៈលក្ខណៈ
នៃធម៌ទាំងឡាយជាកិច្ច

-ផល ឬអាការៈប្រាកដរបស់បញ្ញាចេតសិក

☞អសម្មោហបច្ចុប្បដ្ឋានា មានការមិនវង្វេងជាផល

-ហេតុ ឬបទដ្ឋានរបស់បញ្ញាចេតសិក

☞សមាធិបទដ្ឋានា មានសមាធិជាហេតុជិត ។

**តេរសញ្ញសមានា ច ចុទ្ទសាកុសលា តថា**
**សោភណា បញ្ចវីសាតិ ទ្វិបញ្ញាស បវុច្ចរេ ។**

ប្រែថា អញ្ញសមានាចេតសិក ១៣ អកុសលចេតសិក ១៤ សោភណចេតសិក ២៥ រួមមកចេតសិកមាន ៥២ ប៉ុណ្ណោះ ។

**ចេតសិក ៥២ដែលបណ្ឌិតបានពោលទុកមានប្រការៈយ៉ាងនេះឯង ។**

**សំដែងអំពីសម្បយោគន័យ**

**គាថាសង្គហៈសំដែងទុកថា**

**តេសំ ចិត្តវិយុត្តានំ យថាយោគមិតោ បរំ**
**ចិត្តុប្បាទេសុ បច្ចេកំ សម្បយោគោ បវុច្ចតិ ។**

-

ប្រែថា ការប្រកបព្រមដោយចេតសិកទាំងឡាយ ដែលជាធម្មជាតិ មិនប្រាសចាកអំពីចិត្ត ដែលខ្ញុំ ( ព្រះអនុរុទ្ធាចារ្យ )

នឹងពោលក្នុងចិត្តុប្បាទទាំងឡាយដែលផ្សេង ៗគ្នា ដោយសមគួរតាមការប្រកបដូចតទៅនេះ

ចិត្តនិងចេតសិកដែលប្រកបរួមគ្នាមិនដាច់គឺថាមិនប្រាស់ចាកអំពីគ្នា ហៅថា សម្បយុត្ត ។ លោកសំដែងទុកថា ៖-

**សត្ត សព្វត្ថ យុជ្ជន្តិ យថាយោគំ បកិណ្ណកា**

**ចុទ្ទសាកុសលេស្វេវ សោភណេស្វេវ សោភណា**

ប្រែថា សព្វចិត្តសាធារណចេតសិក ៧ នោះប្រកបចូលក្នុងចិត្តទាំងអស់មិនមានវៀរឡើយ បកិណ្ណកចេតសិក ៦នោះ ឱ្យ

ប្រកបចូលក្នុងចិត្តដែលគួរប្រកប អកុសលចេតសិក ១៤ នោះឱ្យប្រកបចូលក្នុងអកុសលចិត្តទាំង ១២ សោភណចេតសិក

២៥ ឱ្យប្រកបចូលក្នុងសោភណចិត្ត ៥៩ ចិត្ត ៩១ ។

*អធិប្បាយអំពីការប្រកបរបស់ចេតសិកជាមួយនឹងចិត្ត*

សម្បយោគនេះមាន ៤ពួកគឺសព្វចិត្តសាធារណចេតសិក ៧ មានសម្បយោគ ១ ពួកបកិណ្ណកចេតសិកមានសម្បយោគ ៦

ពួកសោភនចេតសិកមានសម្បយោគ ។ បណ្តាសម្បយោគទាំង

៤នេះលោកសំដែងសម្បយោគសព្វចិត្តសាធារណ ចេតសិកទុកជាមុនដូចតទៅនេះ

☞ **សព្វចិត្តសាធារណា តាវ សត្តិមេ ចេតសិកា សព្វេសុបិ ឯកូនគវុតិ ចិត្តុប្បាទេសុ លព្ភន្តិ** ប្រែថា សព្វចិត្តសាធារណចេតសិក ៧ សម្បយោគ ១ ពួកនោះគឺ ( ផស្សៈ វេទនា សញ្ញា ចេតនា ឯកគ្គតា ជីវិតិន្ទ្រិយៈ មនសិការៈ ចេតសិក ៧នេះកើតក្នុងចិត្ត ៨៩ ឬចិត្ត ១២១ ។

( ចប់សម្បយោគសព្វចិត្តសាធារណៈ ៧ )

☞ បកិណ្ណកចេតសិក ៦ មានសម្បយេគ ៦ គឺ ៖-

១-បកិណ្ណកេសុ បន វិតក្កោ តាវ ទ្វិបញ្ចវិញ្ញាណវិជ្ជិតកាមាវចរចិត្តេសុ ចេវ ឯកាទសសុ បឋមជ្ឈានចិត្តេសុ ចាតិ បញ្ច

បញ្ញាសចិត្តេសុ ប្រែថា បណ្តាបកិណ្ណកចេតសិកទាំងឡាយ ចំនែកវិតក្កចេតសិក កើតក្នុងចិត្ត ៥៥គឺ កាមាវចរចិត្ត ៥៤

-

វៀរតែបញ្ចវិញ្ញាណ ១០ ចេញសល់នៅ ៤៤ យកបឋមជ្ឈាន ៨ ជា១១ រួមជាចិត្ត ៥៥ ជាទីកើតនៃវិតក្កចេតសិក ។

២-*វិចារោ* បន តេសុ ចេវ ឯកាទសសុ ទុតិយជ្ឈានចិត្តេសុ ចាតិ ឆសដ្ឋីចិត្តេសុ ប្រែថា ចំណែកវិចារចេតសិកកើតក្នុងចិត្ត

៦៦ គឺ ចិត្តដែលវិតក្កចេតសិកកើតនោះ ៥៥ យករូបាវចរទុតិយជ្ឈាន ៣ និងសលាកុត្តរទុតិយជ្ឈាន ៨ ជា ១១ រួមទាំងអស់ ចិត្ត ៦៦ នេះជាទីតាំងកើតវិចារចេតសិក ។

៣-*អធិមោក្ខោ បន ទ្វិបញ្ចវិញ្ញាណវិចិកិច្ឆាវជ្ជិតចតត្តេសុ* ប្រែថា អធិមោក្ខចេតសិកកើតនៅក្នុងចិត្ត ៧៨ គឺចិត្ត ៨៩ ដួង

វៀរតែទ្វិបញ្ចវិញ្ញាណ ១០ និងវិចិកិច្ឆា ១ចេញនៅសល់ចិត្ត ៧៨ ដួងដែលជាទីកើតរបស់អធិមោក្ខចេតសិក ។

៤-*វីរិយំ* បន បញ្ចទ្វារាវជ្ជនទ្វិបញ្ចវិញ្ញាណសម្បដិច្ឆន្នសន្តីរណាវជ្ជិតចិត្តេសុ ប្រែថា ចំណែកវីរិយចេតសិកកើតក្នុងចិត្ត ៧៣

គឺចិត្ត ៨៩ ដួងវៀរតែបញ្ចទ្វារាវជ្ជនចិត្ត ១ ទ្វិបញ្ចវិញ្ញាណចិត្ត ១០ សម្បដិច្ឆន្នចិត្ត ២ សន្តីរណចិត្ត ៣ នៅសល់ចិត្ត ៧៣ដួង ដែលជាទីកើតរបស់វីរិយចេតសិក ។

៥-បីតី ទោមនស្សុបេក្ខាសហគតកាយវិញ្ញាណចតុត្ថជ្ឈានវជ្ជិតចិត្តេសុ ប្រែថា បីតិចេតសិកកើតក្នុងចិត្ត ៥១ គឺចិត្តពិស្តារ

មាន ១២១ដួងវៀរតែទោមនស្ស ២ ឧបេក្ខា ៥៥ កាយវិញ្ញាណ ២ ចតុត្ថជ្ឈាន ១១ ចិត្តដែលនៅសល់ក្រៅអំពីនេះជាទី

កើតរបស់បីតីចេតសិក ។

៦-ឆន្ទោ អហេតុកមោមូហវជ្ជិតចិត្តេសុ ប្រែថា ឆន្ទចេតសិកកើតក្នុងចិត្ត ៦៩ គឺក្នុងចំណោមចិត្ត ៨៩ ដួងវៀរតែចិត្ត ២០ ដួងចេញចិត្ត ២០នោះគឺអហេតុកចិត្ត ១៨ មោហមូលចិត្ត ២ នៅសល់ក្រៅអំពីនេះជាតាំងកើតរបស់ឆន្ទចេតសិក ។

លោកសំដែងជាគាថាសង្គហៈទុកថា

ឆសដ្ឋិ បញ្ចបញ្ញាស ឯកាទស ច សោឡស

សត្តតិ វិសតិ ចេវ បកិណ្ណកវិវជ្ជិតា ។

បញ្ចបញ្ញាស ឆសដ្ឋ្យ- ដ្ឋសត្តតិ តិសត្តតិ

-

ឯកបញ្ញាស ចេកូន- សត្តតីស បកិណ្ណកា ។

បានសេចក្តីថា ចិត្តទាំងឡាយ ៦៦ ផង ៥៥ ផង ១១ ផង ១៦ ផង ៧០ ផង ២០ ផង វៀរចាកបកិណ្ណកចេតសិកដោយលំដាប់គ្នា ។ ចិត្តទាំងឡាយ ៥៥ ផង ៦៦ ផង ៧៨ ផង ៧៣ ផង ៥១ផង ៦៩ ផង ប្រកបដោយបកិណ្ណកចេតសិកដោយលំដាប់ៗគ្នា ។ មានសេចក្តីអធិប្បាយក្នុងគាថាទាំង ២ នោះថា វិតក្កចេតសិកវៀវ- ចាកចិត្ត ៦៦ កើតក្នុងចិត្ត ៥៥ វិចារចេតសិក វៀរចាកចិត្ត ៥៥ កើតក្នុងចិត្ត ៦៦ អធិមោក្ខចេតសិក វៀរចាកចិត្ត ១១ កើតក្នុងចិត្ត ៧៨ វីរិយចេតសិក វៀរចាកចិត្ត ១៦ កើតក្នុងចិត្ត ៧៣ បីតិចេតសិក វៀរចាកចិត្ត ៧០ កើតក្នុង ៥១ ឆន្ទចេតសិក វៀរចាកចិត្ត ២០ កើតក្នុងចិត្ត៦៩ ។

( ចប់សម្បយោគបកិណ្ណកចេតសិក ៦ )

☞ អកុសលចេតសិក ១៤ មានសម្បយោគ ៧ គឺ ៖-

១-អកុសលេសុ បន មោហោ អហិរិកំ អនោត្តប្បំ ឧទ្ធច្ចញ្ចាតិ ចត្តារោមេ ចេតសិកា សព្វាកុសលសាធារណា នាម សព្វេសុបិ ទ្វាទសាកុសលេសុ លព្ភន្តិ ប្រែថា បណ្តាអកុសលចេតសិកទាំងឡាយ គឺ មោហៈ អហិរិកៈ អនោត្តប្បៈ ឧទ្ធច្ចៈ ទាំង ៤ នេះជាអកុសលសាធារណចេតសិក ( ព្រោះកើតទូទៅក្នុងអកុសលចិត្តទាំង ១២ ដួង ) ។

២-លោភោ អដ្ឋសុ លោភសហគតចិត្តេស្វេវ លព្ភតិ ប្រែថា លោភចេតសិក កើតក្នុងលោភៈមូលចិត្ត ៨ ដួង ។

៣-ទិដ្ឋិ ចតូសុ ទិដ្ឋគតសម្បយុត្តេសុ ប្រែថា ទិដ្ឋិកើតក្នុងលោភចិត្តទិដ្ឋិសម្បយុត្ត ៤ ដួង ។

៤-មានោ ចតូសុ ទិដ្ឋិគតវិប្បយុត្តេសុ ប្រែថា មានចេតសិក កើតក្នុងលោភចិត្តទិដ្ឋិវិប្បយុត្ត ៤ ដួង ។

៥-ទោសោ ឥស្សា មច្ឆរិយំ កុក្កុច្ចញ្ចាតិ ទ្វីសុ បដិឃចិត្តេសុ ប្រែថា ទោសចេតសិក ១ ឥស្សាចេតសិក ១ មច្ឆរិយចេតសិក ១ កុក្កុច្ចចេតសិក ១ ទាំង ៤នេះកើតក្នុងទោសចិត្តបដិឃសម្បយុត្ត ទាំង ២ ដួង ។

៦-ថីនមិទ្ធំ បញ្ចសុ សសង្ខារិកចិត្តេសុ ប្រែថា ថីនចេតសិក និង មិទ្ធចេតសិកទាំង ២ នេះកើតក្នុងសសង្ខារិកចិត្តទាំង ៥។

៧-វិចិកិច្ឆា វិចិកិច្ឆាសហគតចិត្តេយេវ លព្ភតិ ប្រែថា វិចិកិច្ឆាចេតសិក កើតក្នុងចិត្តដែលជាវិចិកិច្ឆាសម្បយុត្ត ។

-

លោកព្រះអនុរុទ្ធាចារ្យសំដែងជាគាថាសង្គហៈទុកថា ៖-

**សព្វាបុញ្ញេសុ ចត្តារោ លោភមូលេ តយោ កតា**

**ទោសមូលេសុ ចត្តារោ សសង្ខារេ ទ្វយន្តថា ។**

**វិចិកិច្ឆា វិចិកិច្ឆា ចិត្តេ ចាតិ ចតុទ្ទស**

**ទ្វាទសាកុសលេស្វេវ សម្បយុជ្ជន្តិ បញ្ចធា ។**

ប្រែថា អកុសលចេតសិកតទាំង ១៤ ប្រកបចូលក្នុងអកុសលចិត្តទាំង ១២ ដួងហើយលោកចាត់ជា ៥ ឋាន ដូច្នេះគឺ

អកុសលចេតសិក កើតក្នុងអកុសលចិត្តទាំង ១២ ។

( ចប់សម្បយោគអកុសលចេតសិក ១៤ )

☞ សោភណចេតសិក ២៥ មានសម្បយោគ ៤ គឺ ៖-

**១-សោភណេសុ បន សោភណសាធារណា តាវ ឯកូនវីសតិ ចេតសិកា សព្វេសុបិ ឯកូនសដ្ឋីសោភណចិត្តេសុ សម្បយុជ្ជន្តិ**

ប្រែថា បណ្តាសោភណចេតសិកទាំងឡាយ ចំណែកសោភណសាធារណចេតសិក ១៩ កើតក្នុងសោភណចិត្ត ៥៩ ។

**២-វិរតិយោ បន តិស្សោបិ អដ្ឋសុ លោកុត្តរចិត្តេសុ សព្វថាបិ និយតា ឯកតោ វ លព្ភន្តិ ។ លោកិយេសុ បន កាមាវចរ**

**កុសលេស្វេវ កទាចិ សន្ទិស្សន្តិ វិសុំ វិសុំ** ប្រែថា ចំណែក វិរតិចេតសិក ៣ ដួងកើតនៅក្នុងលោកុត្តរចិត្ត ៨ ដួង ។ ម្យ៉ាង ទៀតក៏រមែងកើតមានក្នុងកាមាវចរកុសលចិត្ត ៨ ដួង ប៉ុន្តែកើតមានបានតែម្តងម្កាលប៉ុណ្ណោះព្រោះមានអារម្មណ៍ផ្សេងៗ

គ្នាដូច្នេះហើយទើបកើតរួមគ្នាសិន។

**៣-អប្បមញ្ញាយោ បន ទ្វាទសសុ បញ្ចមជ្ឈានវជ្ជិតមហគ្គតចិត្តេសុ ចេវ កាមាវចរកុសលេសុ ច សហេតុកកាមាវចរក្រិ**

**យាចិត្តេសុ ចាតិ អដ្ឋវីសតិចិត្តេស្វេវ កទាចិ នានា ហុត្វា ជាយន្តិ** ។ ប្រែថា ចំណែកអប្បមញ្ញាចេតសិក ២ ដួងកើតក្នុងចិត្ត

-

២៨ គឺ កាមាវចរកុសលចិត្ត ៨ ដួង កាមាវចរកិរិយាចិត្ត ៨ នៅក្នុងមហគ្គតចិត្ត ១៥ វៀរបញ្ចមជ្ឈានចិត្ត ៣ ដួង( ដូច្នេះគឺ
កើតនៅមហគ្គតចិត្តមានតែ ១២ ដួង) រួមមកចិត្ត ២៨ ដួងនេះជាទីកើតរបស់អប្បមញ្ញាចេតសិក ។

**៤-បញ្ញា បន ទ្វាទសសុ ញាណសម្បយុត្តកាមាវចរចិត្តេសុ ចេវ សព្វេសុបិ បញ្ចត្តឹសមហគ្គតលោកុត្តរចិត្តេសុ ចាតិ សត្ត-ចត្តាឡីសចិត្តេសុ សម្បយោគំ គច្ឆតិ** ។ ប្រែថា ចំណែក បញ្ញាចេតសិក កើតក្នុងចិត្ត ៤៧ ដួង គឺ កាមាវចរញាណសម្ប-
យុត្ត ១២ ដួង មហគ្គតចិត្ត ២៧ ដួង លោកុត្តរចិត្ត ៨ ដួង រួមមកត្រូវជាចិត្ត៤៧ ដួងដែលជាទីកើតរបស់បញ្ញាចេតសិក ។

លោកព្រះអនុរុទ្ធាចារ្យអ្នករចនាអភិធម្មត្ថសង្គហបករណ៍នេះបានសំដែងជាគាថាសង្គហៈទុកថាៈ-

**ឯកូនវីសតិ ធម្មា** **ជាយន្តេកូនសដ្ឋិយំ**
**តយោ សោឡសចិត្តេសុ** **អដ្ឋវីសតិយំ ទ្វយំ** ។
**បញ្ញា បកាសិតា សត្ត** **ចត្តាឡីសវិធេសុបិ**
**សម្បយុត្តា ចតុធេវំ** **សោភណេស្វេវ សោភណា** ។

ប្រែថា សោភណចេតសិក ១៩ កើតក្នុងចិត្ត ៥៩ វិរតិចេតសិក ៣ កើតក្នុងចិត្ត ១៦ អប្បមញ្ញាចេតសិក ២ កើតក្នុងចិត្ត ២៨ ។ បញ្ញាចេតសិក កើតក្នុងចិត្ត ៤៧ សោភណចេតសិកទាំងឡាយកើតនៅក្នុងសោភណចិត្ត ប្រកបព្រមហើយដោយ
ប្រការៈ ៤ យ៉ាងដូចន័យដែលបានពោលមកនេះឯង ។

( ចប់សម្បយោគសោភណចេតសិក ២៥ )

## សំដែងអំពីយោគីចេតសិក

យោគីចេតសិកមាន ២ ប្រការគឺ អនិយតយោគីចេតសិក ១ និង និយតយោគីចេតសិក ១ ។ អនិយតយោគី-
ចេតសិកនោះ ជួនកាលកើតរួមជាមួយគ្នា ជួនកាលកើតផ្សេងគ្នាមិនទៀងទាត់ទេ ដោយហេតុនេះហើយទើបលោកហៅ
ថាឈ្មោះ *អនិយតយោគីចេតសិក* មាន ១១ ដូចដែលលោកព្រះអនុរុទ្ធាចារ្យបានសំដែងទុកថាៈ-

-

**ឥស្សាមច្ឆេរកុក្កុច្ច- វិរតិករុណាទយោ**

**នានា កទាចិ មានោ ច ថីនមិទ្ធំ តថា សហ ។**

ប្រែថា ចេតសិកដែលមានឈ្មោះថា ឥស្សា ១ មច្ឆរិយៈ ១ កុក្កុច្ចៈ១ សម្មាវាចា ១ សម្មាកម្មន្តៈ១ សម្មាអាជីវៈ១ ករុណា១ មុទុតា ១ មានៈ១ ថីនៈ១ មិទ្ធៈ១ រួមមកត្រូវជា ១១ ឈ្មោះ *អនិយតយោគីចេតសិក* ។

ចេតសិកមួយពួកទៀតរមែងកើតឡើងទៀងជាមួយគ្នាចេតសិកពួកនោះឈ្មោះថា *និយតយោគីចេតសិក* មាន

ចំនួន ៤១ គឺលោកកំណត់ទុកថា ចេតសិកឯណានីមួយដែលនៅក្រៅពីចេតសិក ១១ដែលជាអនិយតយោគីចេតសិកនោះ

ចេញលោកហៅឈ្មោះថា **និយតយោគីចេតសិក** ។

( ចប់យោគីចេតសិក ២ ពួក )

**សំដែងអំពីសង្គហៈន័យរបស់ចេតសិក ៥២**

ការរួបរួម ឬ ការសង្គ្រោះគឺការរាប់ដួងរបស់ចិត្តនីមួយៗ ដែលចេតសិកកើតរួមជាមួយដើម្បីឱ្យដឹងថា តើចិត្ត-

នោះៗ មានចេតសិកអ្វីខ្លះកើតរួមជាមួយ ដោយន័យដូច្នេះលោកកំណត់ឈ្មោះសង្គហៈ ។ សង្គហៈនោះមាន ៥ ប្រការគឺ

អនុត្តរសង្គហៈ១ មហគ្គតសង្គហៈ១ សោភណសង្គហៈ១ អកុសលសង្គហៈ១ អហេតុកសង្គហៈ១ ។

☞ អនុត្តរសង្គហៈចែកចេញជា ៥ គឺ ៖-

១-បឋមជ្ឈានចិត្តចែកចេញជា ៨ គឺមាន មគ្គ ៤ និង ផល៤ រួមមកត្រូវជា ៨ មានចេតសិកប្រកបជាមួយ ៣៦ គឺ អញ្ញសមានាចេតសិក ១៣ និង សោភណចេតសិក ២៥ដកតែ អប្បមញ្ញាចេតសិក ២ចេញ នៅសល់ ២៣ ដូច្នេះរួមមក ត្រូវជា ៣៦ ។

២-ទុតិយជ្ឈានចិត្តចែកចេញជា ៨ គឺមាន មគ្គ ៤ ផល ៤រួមមកត្រូវជា ៨ មានចេតសិកប្រកបជាមួយ ៣៥ គឺ អញ្ញសមានាចេតសិក ១៣ វៀរតែវិតក្កចេតសិក ១ដួងចេញនៅសល់ ១២សោភណចេតសិក ២៥ វៀរតែអប្បមញ្ញា-

ចេតសិក ២ដួងនៅសល់ ២៣ ដួង ដូច្នេះរួមមកចេតសិកដែលប្រកបជាមួយទុតិយជ្ឈានចិត្តមាន ៣៥ ។

-

៣-តតិយជ្ឈានចិត្តចែកចេញជា ៨ គឺមគ្គ ៤ ផល៤ រួមគ្នាត្រូវជា ៨ មានចេតសិកប្រកបជាមួយ ៣៤ គឺ អញ្ញសមានា-

ចេតសិក ១៣ ដួងវៀរតែ វិតក្កៈនិងវិចារៈ ២ ដួងនេះចេញនៅសល់ ១១ ដួងនិងសោភណចេតសិក ២៥ដួងដកតែចេតសិក

ចំនួន ២ ដួងគឺអប្បមញ្ញាចេតសិកចេញ ដូច្នេះរួមនៅសល់ចេតសិក ៣៤ ដួងដែលប្រកបជាមួយតតិយជ្ឈានចិត្ត ។

៤-ចតុត្ថជ្ឈានចិត្តចែកចេញជា ៨ គឺ មគ្គ ៤ ផល ៤ រួមគ្នាមកត្រូវជា ៨ មានចេតសិកប្រកបជាមួយ ៣៣ គឺ អញ្ញសមានាចេតសិក ១៣ វៀរគឺបានន័យដកវិតក្កៈ១វិចារៈ១បីតិ១នៅសល់ ១០ ដួង សោភណចេតសិក ២៥ វៀរគឺដក

អប្បមញ្ញាចេតសិក ២ ដួងចេញនៅសល់ ២៣ ដូច្នេះចតុត្ថជ្ឈានចិត្តមានចេតសិកកើតរួមជាមួយ ៣៣ ដួង ។

៥-បញ្ចមជ្ឈានចិត្តចែកចេញជា ៨ គឺ មគ្គ ៤ ផល ៤រួមគ្នាមកត្រូវជា ៨ មានចេតសិកប្រកបជាមួយ ៣៣ គឺ អញ្ញសមានាចេតសិក ១៣ដួងវៀរគឺ ដកវិតក្កៈ១ វិចារៈ១បីតិ១ចេញនៅសល់ ១០និងសោភណចេតសិក ២៥វៀរគឺដក

អប្បមញ្ញាចេតសិក ២ ដួងចេញនៅសល់

២៣ដូច្នេះរួមមកបញ្ចមជ្ឈានចិត្តមានចេតសិកប្រកបជាមួយចំនួន ៣៣ដួង ។

( ចប់អនុត្តរសង្គហ ៥ )

☞ មហគ្គតសង្គហៈចែកចេញជា ៥ គឺ ៖-

១-បឋមជ្ឈានចិត្តចែកចេញជា ៣ គឺ កុសល ១ វិបាក ១ កិរិយា១រួមមកត្រូវជា ៣មានចេតសិកប្រកបជាមួយចំនួន៣៥

គឺ អញ្ញសមានាចេតសិក ១៣ និងសោភណចេតសិក ២៥វៀរគឺដកវិរតិ ៣ដួងចេញនៅសល់ ២២ដួងដូច្នេះបឋមជ្ឈានចិត្ត

មានចេតសិកប្រកបរួមជាមួយចំនួន ៣៥ដួង ។

២-ទុតិយជ្ឈានចិត្តចែកចេញជា ៣គឺ កុសល១ វិបាក១ កិរិយា១ រួមមកត្រូវជា ៣មានចេតសិកប្រកបជាមួយ ៣៤ដួងគឺ

-

អញ្ញសមានាចេតសិក ១៣ដួងវៀរតែវិតក្កចេតសិក១ដួងចេញនៅសល់ ១២ ដួង និងសោភណចេតសិក២៥ វៀរគឺដកតែ

វិរតិចេតសិក ៣ ដួងចេញ នៅសល់ ២២ដួងដូច្នេះរួមមកទុតិយជ្ឈានចិត្តមានចេតសិកប្រកបជាមួយចំនួន ៣៤ ដួង ។

៣-តតិយជ្ឈានចិត្តចែកជា ៣គឺ កុសល១ វិបាក១ កិរិយា១ រួមមកត្រូវជា៣ មានចេតសិកប្រកបជាមួយ ៣៣ ដួងគឺ

អញ្ញសមានាចេតសិក ១៣ ដួងវៀរតែវិតក្កៈ១និងវិចារៈ១ចេញនៅសល់ ១១និងសោភណចេតសិក ២៥ វៀរតែវិរតិ-

ចេតសិក ៣ដួងចេញនៅសល់ ២២ ដូច្នេះរួមមកតតិយជ្ឈានចិត្តមានចេតសិកប្រកបជាមួយចំនួន ៣៣ ដួង ។

៤-ចតុត្ថជ្ឈានចិត្តចែកជា ៣គឺ កុសល១ វិបាក១ កិរិយា១ រួមមកត្រូវជា ៣មានចេតសិកប្រកបជាមួយចំនួន ៣២ ដួងគឺ

អញ្ញសមានាចេតសិក ១៣ ដកតែវិតក្កៈ១វិចារៈ១បីតិ១នៅសល់ ១០ ដួងនិងសោភណចេតសិក ២៥ ដកតែ វិរតិ -ចេតសិក ៣ដួងចេញនៅសល់ ២២ ដួងដូច្នេះរួមមកចតុត្ថជ្ឈានចិត្តមានចេតសិកប្រកបជាមួយ ៣២ ដួង ។

៥-បញ្ចមជ្ឈានចិត្តចែកជា ៣គឺ កុសល១ វិបាក១ កិរិយា១រួមមកត្រូវជា ៣ អរូបជ្ឈាន ១២រួមមកទាំងអស់ត្រូវជា ១៥ មានចេតសិកប្រកបជាមួយ ៣០ គឺ អញ្ញសមានាចេតសិក ១៣ ដកវិតក្កៈ១ វិចារៈ១ បីតិ១នៅសល់ ១០និងសោភណ-

ចេតសិក ២៥ ដកវិរតិចេតសិក ៣ដួងនិងអប្បមញ្ញាចេតសិក ២ដួងចេញ ដូច្នេះបញ្ចមជ្ឈានចិត្តនិងអរូបជ្ឈាន មានចេតសិកប្រកបជាមួយ ៣០ ដួង ។

( ចប់មហគ្គតសង្គហៈ ៥ )

សោភណសង្គហៈចែកចេញជា ១២ គឺ កាមាវចរកុសល ៤ កាមាវចរកិរិយា ៤ កាមាវចរវិបាក ៤

កាមាវចរកុសល ៤ គឺបឋមទុក្កៈ ១ ទុតិយទុក្កៈ ១ តតិយទុក្កៈ ១ ចតុត្ថទុក្កៈ ១ ត្រូវជា ៤ទុក្កៈ កាមាវចរវ

កិរិយា និងកាមាវចរវិបាក ក៏ចាត់ចេញជា ៤ចំណែកដូចគ្នាដែរ ដែលហៅថា ទុក្កៈនោះប្រែថាពួក ២គឺចាត់ជាទុក្កៈជាគូរ១

-

នឹងគ្នាទើបហៅថាទុក្កៈក៏នឹងសំដែងកាមាវចរកុសលដែលចាត់ជាទុក្កៈ៧នោះឱ្យឃើញជាបែបយ៉ាងដូច្នេះថាបឋមទុក្កៈនោះ

គឺសោមនស្សសហគតញ្ញាណសម្បយុត្តអសង្ខារិ ១ សសង្ខារិក ១ ។

តតិយទុក្កៈ គឺ ឧបេក្ខាសហគត ញ្ញាណសម្បយុត្ត អសង្ខារិក ១ សសង្ខារិក ១ ។

ចតុត្ថទុក្កៈ គឺ ឧបេក្ខាសហគត ញ្ញាណវិប្បយុត្ត អសង្ខារិក ១ សសង្ខារិក ១ ។

កាមាវចរកិរិយា និង កាមាវចរវិបាក

ក៏ចាត់ទុក្កៈដូច្នេះដូច៧គ្នាប្លែកគ្នាតែគប្បីពិចារណានូវបែបដែលបានធ្វើទុកយ៉ាងនេះ ដូច្នេះចុះ ។

កាមាវចរកុសល ៤សង្គហៈន័យ

១-កុសលបឋមទុក្កៈ មានចេតសិកប្រកប ៣៨គឺ អញ្ញសមានាចេតសិក ១៣ សោភណចេតសិក ២៥ ។

២-កុសលទុតិយទុក្កៈ មានចេតសិកប្រកប ៣៧គឺអញ្ញាមានាចេតសិក ១៣ សោភណចេតសិក ២៥វៀរបញ្ញាចេតសិក ១ ចេញដូច្នេះសោភណចេតសិកប្រកបជាមួយមាន ២៤ ។

៣-កុសលតតិយទុក្កៈមានចេតសិកប្រកប ៣៧គឺអញ្ញសមានាចេតសិក ១៣វៀរបីតិចេតសិក ១ចេញនិងសោភណចេត-សិកដូច្នេះរួមមកមានចេតសិកប្រកប ៣៧ ។

៤-កុសលចតុត្ថទុក្កៈមានចេតសិកប្រកប ៣៦គឺ អញ្ញសមានាចេតសិក ១៣ វៀរបីតិចេតសិក ១ចេញនិងសោភណចេត-

សិក ២៥វៀរបញ្ញាចេតសិក ១ចេញដូច្នេះមានចេតសិកប្រកប ៣៦ ។

កាមាវចរកិរិយា ៤សង្គហៈន័យ

១-កិរិយាបឋមទុក្កៈមានចេតសិកប្រកប ៣៥គឺ អញ្ញសមានាចេតសិក ១៣ និងសោភណចេតសិក ២៥ វៀរវិរតិចេត

សិក ៣ ចេញដូច្នេះមានចេតសិកប្រកប ៣៥ ។

២-កិរិយាទុតិយទុក្កៈមានចេតសិកប្រកប ៣៤ គឺ អញ្ញសមានាចេតសិក ១៣

និងសោភណចេតសិក ២៥វៀរវិរតិចេត

សិក ៣ចេញ ដូច្នេះមានចេតសិកប្រកប ៣៤ ។

៣-កិរិយាតតិយទុក្កៈមានចេតសិកប្រកប ៣៤ គឺ អញ្ញសមានាចេតសិក ១៣

វៀរបីតិចេតសិក១ចេញ និងសោភណ

-

ចេតសិក ២៥ វៀវវិរតិចេតសិក ៣ចេញ ដូច្នេះមានចេតសិកប្រកប ៣៤ ។

៤-កិរិយាចតុត្ថទុក្កៈមានចេតសិកប្រកប ៣៣គឺអញ្ញសមានាចេតសិក ១៣ វៀវបីតិចេតសិក ១ចេញនិងសោភណ-

ចេតសិក ២៥ វៀវវិរតិចេតសិក ៣និងអប្បមញ្ញាចេតសិក១ចេញ ដូច្នេះមានចេតសិកប្រកប ៣៣

កាមាវចរវិបាក ៤ សង្គហៈន័យ

១-វិបាកបឋមទុក្កៈមានចេតសិកប្រកប ៣៣គឺ អញ្ញសមានាចេតសិក ១៣ និង សោភណចេតសិក ២៥ វៀវវិរតិ ៣ និង

អប្បមញ្ញាចេតសិក ២ ចេញដូច្នេះមានចេតសិកប្រកប ៣៣ ។

២-វិបាកទុតិយទុក្កៈមានចេតសិកប្រកប ៣២ គឺ អញ្ញសមានាចេតសិក ១៣ និងសោភណចេតសិក ២៥វៀវវិរតិ ៣និង

អប្បមញ្ញា ២ និងបញ្ញាចេតសិក១ចេញ ដូច្នេះមានចេតសិកប្រកប ៣២ ។

៣-វិបាកតតិយទុក្កៈមានចេតសិក ៣២ គឺអញ្ញសមានាចេតសិក ១៣ វៀវបីតិចេតសិក ១ ចេញនិងសោភណចេតសិក ២៥

វៀវវិរតិ ៣ អប្បមញ្ញាចេតសិក ២ ចេញ ដូច្នេះមានចេតសិកប្រកប ៣២ ។

៤-វិបាកចតុត្ថទុក្កៈមានចេតសិកប្រកប ៣១ គឺ អញ្ញសមានាចេតសិក ១៣វៀវបីតិចេតសិក១ ចេញ និងសោភណចេត

សិក ២៥ វៀវវិរតិ ៣ អប្បមញ្ញា ២ និងបញ្ញាចេតសិក ១ ចេញដូច្នេះមានចេតសិកប្រកប ៣១ ។

( ចប់សោភណសង្គហៈ ១២ )

☞ អកុសលសង្គហៈចែកចេញជា ៧ ពួកគឺ ៖-

សង្គហៈទី ១ គឺសោមនស្សសហគត ទិដ្ឋិគតសម្បយុត្ត អសង្ខារិក សោមនស្សសហគត ទិដ្ឋិគតវិប្បយុត្ត អសង្ខារិក ។

សង្គហៈទី ២ គឺសោមនស្សសហគត ទិដ្ឋិគតសម្បយុត្ត សសង្ខារិក សោមនស្សសហគត ទិដ្ឋិគតវិប្បយុត្ត សសង្ខារិក ។

សង្គហៈទី ៣ គឺទោមនស្សសហគត បដិឃសម្បយុត្តអសង្ខារិក ។

សង្គហៈទី ៤ គឺសោមនស្សសហគត ទិដ្ឋិគតសម្បយុត្ត សសង្ខារិក សោមនស្សសហគត ទិដ្ឋិគតវិប្បយុត្តសសង្ខារិក ។

-

សង្គហៈទី ៥ គឺឧបេក្ខាសហគត ទិដ្ឋិគតសម្បយុត្ត សសង្ខារិក ឧបេក្ខាសហគត ទិដ្ឋិគតវិប្បយុត្តសសង្ខារិក ។

សង្គហៈទី ៦ គឺទោមនស្សសហគត បដិឃសម្បយុត្តសសង្ខារិក ។

សង្គហៈទី ៧ គឺឧបេក្ខាសហគតឧទ្ធចសម្បយុត្ត វិចិកិច្ឆាសម្បយុត្ត ។

អធិប្បាសេចក្តីក្នុងសង្គហៈទាំង ៧ ពួកនោះតទៅថា ៖-

អសង្ខារិកទី ១ មានចេតសិក ១៩ គឺអញ្ញសមានា ១៣ អកុសលសាធារណៈ ៤ លោភៈ១ ទិដ្ឋិ ១ ជា១៩

អសង្ខារិកទី ២ មានចេតសិកប្រកប ១៩ ប្រហែលគ្នានឹងទី ១ ដែរប្លែកគ្នាតែខាងចុង គឺលើកយកទិដ្ឋិចេញដាក់មានៈបញ្ចូលទៅជា ១៩

អសង្ខារិកទី ៣ មានចេតសិកប្រកប ១៨ គឺអញ្ញសមានា ១២ វៀរបីតិ ១ អកុសលសាធារណៈ ៤ និងលោភៈ ១ ទិដ្ឋិ ១ ជា ១៨

អសង្ខារិកទី ៤មានចេតសិកប្រកប ១៨ ប្រហែលគ្នានឹងទី៣ដែរ ប្លែកគ្នាតែខាងចុង គឺលើកយកតែទិដ្ឋិចេញ ដាក់មានៈបញ្ចូលទៅជា ១៨

អសង្ខារិកទី ៥ មានចេតសិកប្រកប ២០ គឺ អញ្ញសមានា ១២ វៀរបីតិ ១អកុសលសាធារណៈ ៤ និងទោសៈ ១
ឥស្សា ១ មច្ឆរិយ ១ កក្កុច្ចៈ ១ ជា ២០

សសង្ខារិកទី ១ មានចេតសិកប្រកប ២១ គឺអញ្ញសមានា ១៣ អកុសលចេតសិក ៨ គឺមោហៈ អហិរិកៈ អនោត្តប្បៈ ឧទ្ធច្ចៈ លោភៈ ទិដ្ឋិៈ ថីនៈ មិទ្ធៈ ជា ២០

សសង្ខារិកទី ២ មានចេតសិកចុះ ២១ ប្រហែលគ្នានិងទី ១ដែរ ប្លែកគ្នាតែខាងចុងគឺលើកយក ទិដ្ឋិចេញដាក់
មានៈបញ្ចូលទៅជា ២១

សសង្ខារិកទី ៣ មានចេតសិក ២០ គឺអញ្ញសមានា ១២ វៀរបីតិ ១ អកុសលចេតសិក ៨ គឺ មោហៈ អហិរិកៈ
អនោត្តប្បៈ ឧទ្ធច្ចៈ លោភៈ ទិដ្ឋិៈ ថីនៈ មិទ្ធៈ ជា២០

សសង្ខារិកទី ៤ មានចេតសិកចុះ ២០ ប្រហែលគ្នានិងទី ៣ ប្លែកគ្នាតែខាងចុងគឺលើកយកទិដ្ឋិចេញដាក់មានៈ

-

បញ្ចូលទៅជា ២០

សសង្ខារិកទី ៥ មានចេតសិកប្រកប ២២ គឺអញ្ញសមានា ១២ វៀរបីតិ ១ អកុសលចេតសិក ១០ គឺ មោហៈ អហិរិកៈ អនោត្តប្បៈ ឧទ្ធច្ចៈ ទោសៈ ឥស្សា មច្ឆរិយៈ កុក្កុច្ចៈ ថីនៈ មិទ្ធៈ ជា ២២

មោហឧទ្ធច្ចសម្បយុត្ត មានចេតសិកប្រកប ១៥ គឺ អញ្ញសមានា ១១ វៀរឆន្ទៈ ១ បីតិ ១ អកុសលសាធារណៈ ៤ជា ១៥

មោហវិចិកិច្ឆាសម្បយុត្ត មានចេតសិកប្រកប ១៥គឺ អញ្ញសមានា ១១ វៀរបីតិ ១ អធិមោក្ខៈ អកុសលសាធារណៈ ៣ គឺ មោហៈ អហិរិកៈ អនោត្តប្បៈ និង វិចិកិច្ឆា ១ ជា ១៥ ។

(ចប់អកុសលសង្គហៈ ៧)

☞ អហេតុកសង្គហៈសង្គ្រោះដោយចេតសិកចុះក្នុងអហេតុកចិត្ត ១៨ចែកចេញ ៤ សង្គហៈ គឺ ៖-

១-សង្គហៈទី ១ គឺ ហសិតុប្បាទចិត្ត មានចេតសិកប្រកប ១២ គឺអញ្ញសមានា ១២ វៀរឆន្ទៈ ១

២-សង្គហៈទី ២ គឺ វោដ្ឋព្វនចិត្ត មានចេតសិកប្រកប ១១ គឺអញ្ញសមានា ១១ វៀរឆន្ទៈ ១ បីតិ ១ សុខសន្តីរណៈមានអញ្ញសមានាប្រកប ១១ វៀរឆន្ទៈ ១ វីរិយៈ ១

៣-សង្គហៈទី ៣ គឺ បញ្ចទ្វារាវជ្ជនៈ ១ អកុសលសម្បដិច្ឆន្នៈ ១ កុសលសម្បដិច្ឆន្នៈ ១ បីនេះឈ្មោះមនោធាតុតិក្កៈ អកុសលសន្តីរនៈ ១ កុសលសន្តីរណៈ ១ ពីរនេះឈ្មោះបដិសន្ធិបុគ្គល មានអញ្ញសមានាប្រកប១០ វៀរឆន្ទៈ ១ បីតិ ១ ។

៤-សង្គហៈទី ៤គឺ ទ្វិបញ្ចវិញ្ញាណ មានសព្វចិត្តសាធារណៈប្រកបទាំង ៧ វៀរបកិណ្ណកៈទាំង ៦ ។

(ចប់អហេតុកសង្គហៈ ៤)

អភិធម្មត្ថសង្គហៈ

(បរិច្ឆេទទី ២ ចេតសិកសង្គហៈវិភាគ ចប់ដោយសង្ខេប)

-

-